**BMI0039**

# សម្ភាសន៍ជាមួយឈ្មោះ គង់ វ៉ាន់ថេង ភេទប្រុស អាយុ៥០ឆ្នាំ

មុខងារសម័យខ្មែរក្រហមៈ កម្មកររទេះភ្លើងថ្មី

មុខងារបច្ចុប្បន្នៈ កសិករ

ស្រុកកំណើតនៅភូមិឈើទាលភ្លោះ ឃុំកញ្ជរ ស្រុកឆ្លូង ខេត្តក្រចេះ

សព្វថ្ងៃរស់នៅភូមិកណ្តាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឆាយ ឈុនលី

០១:០៧:១០

២៨ទំព័រ

ឈុនលី ៖ ដំបូងខ្ញុំសុំឲ្យពូជួយប្រាប់ឈ្មោះ ។ ពូឈ្មោះអីគេ?

ថេង ៖ គង់ វ៉ាន់ថេង ។

ឈុនលី ៖ អាយុប៉ុន្មាន?

ថេង ៖ ៥០ ។

ឈុនលី ៖ ស្រុកកំណើតនៅណា?

ថេង ៖ ដាក់ភូមិម៉ង់ ភូមិឈើទាលភ្លោះ ឃុំកញ្ជរ ស្រុកឆ្លូង ខេត្តក្រចេះ ។

ឈុនលី ៖ ពូកាលនឹងមានបងប្អូនប៉ុន្មាននាក់?

ថេង ៖ ហ្នឹងយើងនិយាយរស់?

ឈុនលី ៖ ចា៎! និយាយតាំងពីដើមថាមានបងប្អូនប៉ុន្មាននាក់ ។

ថេង ៖ ៩ ។

ឈុនលី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ថេង ៖ ស្រី៤ ប្រុស៥ ។

ឈុនលី ៖ ឪពុកម្តាយពូធ្វើអី?

ថេង ៖ ប្រជាជនធម្មតា ។

ឈុនលី ៖ កសិករ?

ថេង ៖ បាទ!

ឈុនលី ៖ កាលរបបពឆ្នាំនឹង ពូមានជម្លៀសទៅណា?

ថេង ៖ ខ្ញុំមកនៅភ្នំពេញ ។

ឈុនលី ៖ ឆ្នាំប៉ុន្មាន?

ថេង ៖ ឆ្នាំ៧៧ ។

ឈុនលី ៖ ចុះឆ្នាំ៧៥?

ថេង ៖ ៧៥ នៅផ្ទះ ។

ឈុនលី ៖ អត់មានជម្លៀសទៅណាទេ?

ថេង ៖ អត់ទេ ។

ឈុនលី ៖ កាលនឹងពូអាយុប៉ុន្មានទៅ?

ថេង ៖ ១៧ដែរ ។

ឈុនលី ៖ នៅភ្នំពេញតាំងពីឆ្នាំណាដែរ?

ថេង ៖ ១៩៧៧នឹង យើងរំដោះភ្នំពេញបាន យើងវៃជាមួយអាមេរិច ដល់៧៥ យើងរំដោះភ្នំពេញ ដល់៧៧ខ្ញុំឡើងមកភ្នំពេញ កម្មកររទេះភ្លើង ។

ឈុនលី ៖ កម្មកររទេះភ្លើង ធ្វើអីខ្លះ?

ថេង ៖ នៅកម្មកររទេះភ្លើងថ្មីធ្វើលូ ធ្វើស្ពាន ខាងធ្វើស្ពាន និយាយរួមធ្វើផ្លូវរទេះភ្លើងថ្មីមិនទាន់បានសម្រេចទេ ។

ឈុនលី ៖ នៅផ្លូវរទេះភ្លើង ដូចកន្លែងដែលពូធ្វើអានឹងគេហៅអីគេ?

ថេង ៖ ហ្នឹងហើយកាលសម័យនឹងយើងផែនការយើងបង្កើតផ្លូវរទេះភ្លើងថ្មី ពីភ្នំពេញទៅកំពង់សោម ហើយយើងកាត់តាមភ្នំពេជ្រនិលនឹង ។ ដល់ពេលឆ្នាំ៧៩ យើងមានសង្គ្រាមមក វាត្រូវបរាជ័យអាផ្លូវនឹងវិញ អត់បានធ្វើបាន ។

ឈុនលី ៖ ចឹងវ៉ាគេនៅកន្លែងណា ដែលពូស្នាក់នៅកន្លែងពូនៅធ្វើការ?

ថេង ៖ ពួកខ្ញុំអត់នេះទេ គឺចល័ត ធម្មតាយើងធ្វើស្ពានហើយនឹងលូ យើងធ្វើចាប់ពីភ្នំពេញទៅ ពីសំរោងទៅៗរហូតដល់កំពង់សោម ។ ចឹងយើងធ្វើមានច្រើនកន្លែងណាស់ មានទាំងស្ពាននៅមហាសាំង គេហៅខាងស្រែថ្កុង ខាងដូចវាច្រើនកន្លែងស្ពានដែរ លូដែរ ។ យើងមានកំណត់វ៉ាណា មិនទាន់មានវ៉ាណា ព្រោះផ្លូវរទេះភ្លើងថ្មីយើងទើបបង្កើតផ្លូវ ។ ចឹងគម្រោងទី១ យើងត្រូវធ្វើស្ពានធ្វើលូ ផ្លូវរត់តាមក្រោយប៉ុនដូចខ្ញុំបញ្ជាក់ខាងលើមិញចឹង ។

ឈុនលី ៖ បរាជ័យវិញ?

ថេង ៖ ហ្នឹងបរាជ័យវិញ ។

ឈុនលី ៖ ហ្នឹងដោយសារអីគេ?

ថេង ៖ សង្គ្រាមកាលនោះយើង៧៩ នែក!ខាងវៀតណាមចូលមកចឹងវ៉ៃគ្នា សង្គ្រាមមិនកើតឡើង ។

ឈុនលី ៖ ពួជម្ទៀសមកខាងនេះ?

ថេង ៖ បាទ! ដល់ពេល៧៩មកយើងចេះរត់មកនេះ ។

ឈុនលី ៖ រត់មកតាមគេតាមឯង?

ថេង ៖ ហ្នឹង! មកតាមគេតាមឯងមកដល់នឹង ។

ឈុនលី ៖ មកដល់ជំបូងនៅនឹងបណ្តោយ?

ថេង ៖ មកដល់នៅនឹងបណ្តោយ ប៉ុនតែ ។

ឈុនលី ៖ សភាពការណ៍នៅនេះម៉េចទៅ?

ថេង ៖ វាពិបាកណាស់កាលនឹង គិតទៅមនុស្សរាប់ម៉ឺននាក់ត្រូវស្លាប់ដោយសារអត់បាយ ហើយជម្ងឺគ្រុនចាញ់ ។ ហើយធម្មតាយើងមកវាមានខបសក្តច្រើនណាស់ ព្រៃច្រើនដងអីជង សំខាន់មនុស្សអត់បាយដែរយើងមកដល់ព្រំដែនឆ្នាំ៧៩ បានមានអង្ករហូប ។

ឈុនលី ៖ អ្នកណាអ្នកចែកអង្ករចែកអី?

ថេង ៖ អង្ករនឹងគឺ ខាងនោះគេហៅខាងរដ្ឋាភិបាលយើងដែរ អ្នកដឹកនាំយើងនឹងបានទំនាក់ទំនងមកតាមរយៈចិន ថៃនឹងមក ។

ឈុនលី ៖ អ្នកដឹកនាំនៅក្នុងតំបន់នឹង?

ថេង ៖ បាទ! តំបន់យើង ។

ឈុនលី ៖ កាលនឹងអ្នកណាគេទៅ?

ថេង ៖ អានឹងអ្នកកំពូលៗនឹងមានប៉ុលពត មាននេះនឹង អ៊ំខៀវ សំផន អៀង សារី កាលនឹងគាត់សម័យនោះ គាត់អ្នកដឹកនាំផ្ទាល់នៅប្រទេសខ្មែរយើង ។ ការសង្គ្រាមចឹងមក មានការច្បាំងគ្នាមក គាត់ក៏ទំនាក់ទំនងខាងបរទេសនឹងមក ដើម្បីយកអង្ករជួយអ្នកជនរងគ្រោះ ។

ឈុនលី ៖ កាលនឹងខ្ទង់៧៩?

ថេង ៖ បាទ! ហ្នឹងជួយអ្នករងគ្រោះដែលមានសង្គ្រាម ។ ហើយសំខាន់ខាងកាកបាទក្រហមជងដែរ ។

ឈុនលី ៖ កាកបាទក្រហមប្រចាំនៅថៃនឹង?

ថេង ៖ ហ្នឹងកាកបាទក្រហមគេជួយលើពិភពលោក ដូចថាប្រទេសណាដែលកើតសង្គ្រាមគេនឹងជួយចឹងយើងបានអង្ករហូប ថ្នាំពេទ្យនឹង ។

ឈុនលី ៖ ពេលរត់ចេញមកចឹង ហើយវៀតណាមដេញតាម?

ថេង ៖ ហ្នឹង គេដេញតាមរហូតមកចឹងកង់ទ័ព ។

ឈុនលី ៖ ចុះពេលយើងមកនៅនេះហើយ មានគេមកតាមទៀត?

ថេង ៖ បាទ! ប្រហែលរហូតដល់នឹង កន្លែងនេះអីគេយកអស់ហើយ គិតទៅយើងមកនៅនេះបាន ៧៩ដល់ឆ្នាំ៨៥ៗយើងត្រូវរត់ចេញពីនេះទៅនៅដីថៃ។

ឈុនលី ៖ ពូចេញទៅជាមួយគេ ជាមួយឯង?

ថេង ៖ ចេះទៅៗ ។

ឈុនលី ៖ ចង់ដឹងថាពេលមកនឹងគ្នាច្រើន?

ថេង ៖ ច្រើន មក ។

ឈុនលី ៖ មានអ្នកណាខ្លះដែលមក ដូចមានប្រភេទទ័ពផងអីផង?

ថេង ៖ ហ្នឹង មានកងទ័ព ហើយពួកខ្ញុំកម្មករ...ភ្នំពេញ ។ មកកងទ័ពគេនៅតាមក្រោយនោះ ប៉ុន យើងកម្មករគេឲ្យមកមុន ។

ឈុនលី ៖ ម៉េចបានគេឲ្យទ័ពនៅតាមក្រោយ?

ថេង ៖ ទ័ពនៅទប់ទល់ជាមួយវៀតណាម ។

ឈុនលី ៖ វ៉ៃបណ្ដើររត់បណ្ដើរ?

ថេង ៖ បាទៗ ។

ឈុនលី ៖ ប្រហែលជាប៉ុន្មាននាក់ទៅ?

ថេង ៖ ហឺ! ច្រើនណាស់ មិនលាក់ទេ រាប់ម៉ឺនរាប់សែន ។

ឈុនលី ៖ ឲ្យធ្វើដំណើរដោយអីទៅ ដើរ?

ថេង ៖ ដើរ ។

ឈុនលី ៖ ប៉ុន្មានយប់មកដល់នេះ?

ថេង ៖ យើងចេញពីភ្នំពេញមកដល់នេះខែ៨បានមកដល់ ។

ឈុនលី ៖ ខែ៨ ៧៩?

ថេង ៖ បាទ!

ឈុនលី ៖ ចឹងបែកពីភ្នំពេញតាំងពីខែ១ ២-៣ខែ?

ថេង ៖ ហ្នឹង ។

ឈុនលី ៖ ចឹងមានដើរឈប់ៗ?

ថេង ៖ ដើរឈប់ដើរសម្រាកតាមភូមិ ។ កាលនោះវាស្មានមិនដល់ថាសង្គ្រាមវាដល់ប៉ុននឹងទេ ។

ឈុនលី ៖ យើងគិតថាចប់ហើយ?

ថេង : បាទ! យើងគិតថា វាជាសង្គ្រាម...យើងនៅក្មេងដែរ យើងអត់ទាន់បានគិតដល់យើងថាដូចជាសង្គ្រាមនឹងវាមិនមែនវាអនាគតទេ វាអាចវិលត្រឡប់ទៅវិញ ។ មិនដឹងថាយើងនឹងរត់រហូតមកចឹងអី គេថាអាច៣-៤-៥ថ្ងៃយើងអាចចូលស្រុកវិញហើយ ។ ដល់មកមិនមែនចឹងណារហូត ។

ឈុនលី : ចឹងពេលគេប្រាប់នឹងគេថាមកតែប៉ុន្មានថ្ងៃ មកម៉ាំរយៈ?

ថេង : ហ្នឹង គេឃោសនា ។

ឈុនលី : ចុះដូចពូធ្វើកម្មករនឹង ប្រធានកាន់កាប់ខាងកម្មករមកដែរ?

ថេង : មកទាំងអស់ ។

ឈុនលី : កាលនឹងអ្នកណាគេអ្នកកាន់កាប់?

ថេង : ឈ្មោះបងយុន យើងកាលនោះយើងមិនសូវប្រើជាត្រកូលទេ យើងហៅថាបងយុនៗព្រោះគាត់បងៗយុន ។

ឈុនលី : គ្រប់នៅរោងចក្រ?

ថេង : អគ្គភាពរទេះភ្លើងថ្មី ។

ឈុនលី : អានឹងគេហៅអគ្គភាពអីគេ?

ថេង : រទេះភ្លើងថ្មី ។

ឈុនលី : ដោយសារមានគម្រោងថ្មីនឹង?

ថេង : បាទ! បើសិនជាយើងបានធ្វើរទេះភ្លើងនឹងបាន អាចដឹកជញ្ជូនរបស់យើងល្អ ព្រោះយើងធ្វើ២ខ្សែ មិនដូចយើងរាល់ថ្ងៃ ២ខ្សែវាវែ២ចេះក្បាលរទេះភ្លើងមួយមក មួយទៅ ។ ហើយគេអាចមានផែនការរំលាយភ្នំពេជ្រនិល រូង ដូចស្រុកចិន ។

ឈុនលី : ធ្វើរបៀបឆ្លងកាត់រូង?

ថេង : បាទ! រូងភ្នំកាត់ទៅកំពង់សោមតែម្ដង វាអត់វាងទៅកំពតហើយបានមកកំពង់សោម ។

ឈុនលី : អានេះលឿន?

ថេង : នេះលឿនផ្លូវកាត់ត្រង់ ធ្វើម៉េចសង្គ្រាម ដល់សង្គ្រាមរលាយ ។

ឈុនលី : ដល់ពេលឥឡូវគេធ្វើផ្លូវរទេះភ្លើងថ្មី គេធ្វើកាត់កែប កំពតអីនោះ រាល់ថ្ងៃនេះកំពុងធ្វើ ។

ថេង : អាជួសជុលផ្លូវចាស់ទេ ។

ឈុនលី : ចឹងផ្លូវនឹង ដែលពូ?

ថេង : អាផ្លូវនឹងផ្លូវចាស់ទេ ដែលធ្វើពីភ្នំពេញទៅកែប-កំពតនឹង ផ្លូវចាស់ទេ អាផែនការដែលធ្វើថ្មីនឹង គឺដឹកពីភ្នំពេញសំរោងកាត់ត្រង់ភ្លឹងកាត់ទៅកំពង់សោម ។

ឈុនលី ៖ អានេះជិត?

ថេង ៖ បាទ! ជាទន្ទឹមនឹងផ្លូវជាតិលេខ៤ រួងភ្នំពេជ្រនិល ។

ឈុនលី ៖ ពូបានធ្វើចេញជាសាច់ការអីខ្លះ?

ថេង ៖ កាលនឹងយើងបានលើកចាប់ពីសំរោងតៗពីភ្នំពេញមក គេហៅសំរោងតាំងក្រសាំង ។

ឈុនលី ៖ អានឹងស្រុក ខេត្តអីគេ កែប?

ថេង ៖ ជាប់នឹងតាំងក្រសាំង ចេញពីភ្នំពេញ ខាងលិច អានឹងយើងធ្វើចាប់ពីនឹងមករហូតដល់ពេជ្រនិលហើយ ។

ឈុនលី ៖ ចង់សួរថាពូទៅថៃនឹងតាំងពី៨៥ ចុះខ្វង់៨២ ៨១ ៨២ ៨៣ ស្ថានភាពម៉េចទៅ?

ថេង ៖ វានៅនេះលែងអីហើយ និយាយរួមទៅយើងលំបាកតែកាលឆ្នាំ១៩៧៩ ដែលយើងលំបាកដល់ឡើង៨០ឡើងមកវិញ គឺបានធូរធា មានហូបមានចុកគ្រប់គ្រាន់អត់មានអីលំបាកទេ ។ តែគ្រាន់តែថាវាលំបាកផ្លូវចិត្តមួយគឺថាយើងបែកបាក់បងប្អូន ។

ឈុនលី ៖ ចឹងពេលរត់មកនឹង អត់មានបងប្អូនពូមកជាមួយទេ?

ថេង ៖ អត់ទេ ។

ឈុនលី ៖ ម្នាក់ឯង?

ថេង ៖ បាទ! ព្រោះយើងធ្វើជាកម្មករ ។

ឈុនលី ៖ ចុះម៉េចក៏ពូអត់រត់ចេញទៅស្រុកកំណើត ឬមួយក៏គេចទៅខេត្តណាផ្សេង?

ថេង ៖ អត់បាន ព្រោះកាលនោះយើង ព្រោះអីជិះមកជាអន្តភាព ។

ឈុនលី ៖ យើងរត់ខ្លាចគេចាប់?

ថេង ៖ បាទ! បើសិនជាយើងរត់ចេញទៅក្រៅគេចាប់យើង ។

ឈុនលី ៖ ដូចមកចឹង មានវៀតណាមដេញតាមក្រោយ ពូថាមានដេញតាមក្រោយ ចុះអាខ្វង់៨០ ៨១នឹង មានច្បាំងគ្នាច្បាំងអី?

ថេង ៖ អានឹងបានខ្លាំង ។

ឈុនលី ៖ អានឹងខ្លាំងម៉េច?

ថេង ៖ ច្បាំងគ្នាខ្លាំងម៉ង ។

ឈុនលី ៖ តំបន់នេះមុនដំបូងគេហៅតំបន់អីគេ?

ថេង ៖ វាគេហៅតំបន់១០២ បើយើងប្រើលេខតំបន់១០២ ។

ឈុនលី ៖ គេអត់ហៅម៉ាឡៃចឹងទេ?

ថេង ៖ ម៉ាឡៃយើងទើបប្រើស្រុកទេ យើងបង្កើតស្រុកមកយើងដឹងម៉ាឡៃ ។

ឈុនលី ៖ ក្រោយសមាហរណកម្ម?

ថេង ៖ ហ្នឹងហើយ! វាមែនទែនម៉ាឡៃកាលនោះអាតំបន់ស្មើស្រុក១០២យើងប្រើលេខ ដល់ក្រោយមកយើងលុបតំបន់១០២វិញ យើងដាក់ស្រុកម៉ាឡៃ ។

ឈុនលី ៖ កាលនោះអ្នកណាគេគ្រប់គ្រងស្រុកនឹង?

ថេង ៖ លោក ឈឹម មុនី ឥឡូវគាត់នៅខេត្ត ។

ឈុនលី ៖ គាត់នៅខេត្តធ្វើអី?

ថេង ៖ អធិការកិច្ច ។

ឈុនលី ៖ ពូថាច្បាំងចឹង ពូចូលតាមពីណា?

ថេង ៖ ដល់យើងឆ្នាំ៨១មកយើងចូលធ្វើទាហានទៅ ។

ឈុនលី ៖ ពេលនឹងពូចាប់ផ្តើមចូលធ្វើទាហាន?

ថេង ៖ បាទ!

ឈុនលី ៖ កាលនឹងម៉េចបានចូល ត្រូវតែចូល?

ថេង ៖ វាត្រូវតែចូល ព្រោះអីអ្នកដែលតស៊ូទាំងអស់ គ្មានអ្នកណាគេចពីទាហានមួយ ។

ឈុនលី ៖ អានឹងគេថាឲ្យតែចូលដល់នឹង គេហៅអ្នកតស៊ូម៉ង?

ថេង ៖ បាទ! តស៊ូទាំងអស់ ។

ឈុនលី ៖ ហើយចឹងគេហាត់រៀនអីទេ ព្រោះយើងដំបូង?

ថេង ៖ រៀន ប៉ុនរៀនបានតិចតួច រៀនដែរ រៀនខាងផ្នែកយោធាខាង ។

ឈុនលី ៖ ចុះឆ្នាំណាគេដាក់មីងនៅតំបន់នឹង?

ថេង ៖ មីនគេប្រើតាំងពីឆ្នាំ១៩៨០ ៨១ ៨២ហ្នឹងហើយ ប្រើហើយ ។

ឈុនលី ៖ អ្នកណាគេអ្នកដាក់មីនទាំងអស់?

ថេង ៖ ទ័ពវាទាំងអស់អ្នកនៅនឹង ។

ឈុនលី ៖ ទ័ពណា?

ថេង ៖ និយាយរួមទាំងសងខាង ខាងយើងចាស់នៅនេះក៏ដាក់ ដល់គេមកពីនោះក៏ដាក់ដែរ ខាងរដ្ឋកម្ពុជា ដែលយើងចេញពីនេះឆ្នាំ ។

ឈុនលី ៖ ទ័ពចាស់ខាងណា?

ថេង ៖ ខាងខ្មែរក្រហមយើង ។ ហើយដល់ពេលយើងចេញទៅ ឆ្នាំ៨៥ យើងមិនរត់ចេញពីនេះទៀត ដល់រដ្ឋកម្ពុជាគេមកតាមព្រំដែនដាក់ម៉ាសារទៀត ចឹងមីនដាក់ ។

ឈុនលី ៖ អូ! ខាងរដ្ឋកម្ពុជាទៀត?

ថេង ៖ បាទ! ខាងយើងប្រើប្រាស់តាមគេ ដូចថាតាមត្រីចំនុចៗ ដល់រដ្ឋកម្ពុជាមក គេដាក់តាមព្រំដែនរហូតមក ។

ឈុនលី ៖ ដាក់ៗចង់ឲ្យដុះខ្មែរផាប់?

ថេង ៖ បាទ! គេប្រើតាមព្រំដែន ហើយយើងប្រើតែតំបន់ណាដែលឆ្ងកាត់ចឹង ដាក់ទៅតាមមាត់អូរ ។

ឈុនលី ៖ ចុះមុនពេលវត់នឹងបាញ់គ្នាខ្លាំង ហេតុអីបានខ្មែរក្រហមរត់ទៅថៃវិញ?

ថេង ៖ វាវៃមកខ្លាំងហើយ ។

ឈុនលី ៖ យើងទប់ទល់អត់ឈ្នះ?

ថេង ៖ អត់ឈ្នះទេ ។

ឈុនលី ៖ ចុះកាលនឹងយើងទប់ទល់ជាមួយវៀតណាម ឬមួយជាមួយរដ្ឋកម្ពុជាដែរ?

ថេង ៖ វា ធម្មតាទេ មុនដំបូងគឺវៀតណាមនឹងហើយ ប៉ុនដល់ពេលក្រោយមកគេវៀតណាមត្រូវខាងអង្គការសហប្រជាជាតិនឹង ត្រូវឲ្យដកចេញពីប្រទេសកម្ពុជា ចឹងគ្រាន់ជាជំនាញការទេ ក្រោយមកគឺខ្មែរនិងខ្មែរ ។

ឈុនលី ៖ ចឹងប្រហែលឆ្នាំណាដែលវៀតណាមចេញទៅ?

ថេង ៖ ឆ្នាំ៩៣ ។

ឈុនលី ៖ ពេលបោះឆ្នោត?

ថេង ៖ អឺ! មុនបោះឆ្នោត៩៣ ។

ឈុនលី ៖ ដល់ពេលបន្ទាប់ពីបោះឆ្នោតហើយនឹង យើងខ្មែរគ្នាឯងជាមួយរដ្ឋកម្ពុជា?

ថេង ៖ បាទ! យើងកាលនោះ យើងចាប់ពី៩៣មក វាសភាពការណ៍រៀងធូរហើយណា ។

ឈុនលី ៖ អានឹងពេលនឹងមកពីជំរំវិញហើយមែនទេ?

ថេង ៖ បាទ! មកហើយ ។

ឈុនលី ៖ ជំរំអីគេ?

ថេង ៖ ជំរំទី៨ សាយអេច ជំរំទី៨ ។

ឈុនលី ៖ ជំរំទី៨?

ថេង ៖ អឺ!

ឈុនលី ៖ មិនមែន៨៥?

ថេង ៖ អានឹងគេហៅខ-៨៥ ។

ឈុនលី ៖ ឈ្មោះដូចគ្នា?

ថេង ៖ បាទ! ប៉ុនបើ គេហៅជំរំខ-៨៥ ។

ឈុនលី ៖ ចុះជំរំតាង៉ុកនៅណា?

ថេង ៖ អានឹងជំរំសាយអេច ជំរំទី៨ ជំរំ២ ។

ឈុនលី ៖ អាមួយជំរំខ-៨៥ អាមួយទៀត?

ថេង ៖ ហ្នឹង មួយសាយអេចៗទីប៉ុន្មានជំរំគេផ្សេង ប៉ុនខ្ញុំៗនៅនេះ ។

ឈុនលី ៖ ៨៥?

ថេង ៖ បាទ!

ឈុនលី ៖ កាលនឹងគេខបត្តម្ពស្បៀង?

ថេង ៖ បាទ! ធម្មតា ។

ឈុនលី ៖ ទាហានខ្មែរក្រហមទាំងអស់ គេរត់ទៅនឹងទាំងអស់?

ថេង ៖ បាទ!

ឈុនលី ៖ ហើយចឹងពូត្រឡប់មកវិញពេលណា?

ថេង ៖ ឆ្នាំ១៩៩០ ៩១កាលនឹង ។

ឈុនលី ៖ យូរម៉េច ចុះមានអ្នកខ្លះគេរត់មកមុនដែរ?

ថេង ៖ អត់មានទេ ៩០យើងត្រឡប់ចេញពីដីថៃមកនៅយើងនេះវិញ ។

ឈុនលី ៖ មិនមែនមក៨៧អីទេ?

ថេង ៖ អត់ទេ ។

ឈុនលី ៖ ចុះ៨៧ ៨៨ យើងនៅក្នុងនឹងនៅឡើយ?

ថេង ៖ យើងនៅនឹងដែរ ។

ឈុនលី ៖ ចុះពូ(មេភូមិកណ្តាល) បានរត់ទៅជាមួយគេដែរ?

ថេង ៖ ទៅជាមួយគ្នា និយាយស្រុកនេះទៅសម្អាសន៍ម្នាក់ដូចទាំងអស់ ។

ឈុនលី ៖ ប៉ុន្តែសាច់រឿងពីដើមមកខុសគ្នា ។

ថេង ៖ ហ្នឹង ប៉ុនគ្រាន់ថាវាទៅនោះខ្លះដោយសារឆ្នាំ៧៥ ៧៦អីវាខុសគ្នា ។

ឈុនលី ៖ បើកន្លែងនេះពូថាអត្តភាពៗ?

ថេង ៖ រទេះភ្លើង ។

ឈុនលី ៖ រទេះភ្លើងថ្មី?

ថេង ៖ ហ្នឹង ។

ឈុនលី ៖ ត្រឡប់មកវិញឆ្នាំ៩១ ចុះពេលមកវិញយ៉ាងម៉េចទៅស្ថានភាពនេះ នៅព្រៃដែល?

ថេង ៖ វាមែនទែនទៅព្រៃវាមិនសូវមានប៉ុន្មានទេ ប៉ុនវាមាន... យើងវាអត់សូវមានព្រៃតាំងពីកាលដែលយើងនៅបានប៉ុន្មាន មក៧៩រហូតដល់៨៥ ។ ចឹងម៉ុំនេះផ្ទះសម្បែងវាច្រើនដូចចឹង ។

ឈុនលី ៖ ចឹងពេល៧៩ មក៨៥នឹងនាំគ្នាកាប់ឆ្ការព្រៃនៅបណ្ដោយ?

ថេង ៖ បាទ! យើងបង្កើតជាមូលដ្ឋាន មានផ្ទះរឹងប៉ឹងនឹង ។

ឈុនលី ៖ ប៉ុន្តែអត់ទាន់មានមីនទេ?

ថេង ៖ អត់មានទេ យើងអត់ប្រើ មាន ។

ឈុនលី ៖ អស់ព្រៃខ្លះហើយ?

ថេង ៖ មានទើបខាងរដ្ឋកម្ពុជាមកដាក់ទេ តាមមាត់អូរ ។

ឈុនលី ៖ ពេលគេមកដាក់នឹង ដាក់ឆ្នាំ៨៥?

ថេង ៖ ៨៥ ។

ឈុនលី ៖ ពេលដែលយើងចេញទៅភ្នាម?

ថេង ៖ ទៅភ្នាម ហ្នឹងគេដាក់ឆ្នាំ១៩៨៥ រហូតដល់យើងត្រឡប់មកវិញហ្នឹងដោះមីននឹង ត្រូវមីនច្រើនណាស់ ។

ឈុនលី ៖ ពេលមកវិញនឹង ស្លាប់នឹងត្រូវមីនច្រើន?

ថេង ៖ បាទ! ពេលគេចេញទៅវាបន្សល់ទុកអាមីននឹង ។

ឈុនលី ៖ ហើយចឹង ពេលមកនឹង គេចែកដីចែកអីនៅ?

ថេង ៖ ដីយើងនៅតាមអង្គភាព កាលនោះយើង ។

ឈុនលី ៖ ចឹងបានន័យថាពេលយើងទៅនោះ អង្គភាពយើងទៅទាំងអស់ ដល់ពេលមកវិញរត់ចូលអង្គភាពវិញ?

ថេង ៖ ហ្នឹងទៅទាំងអង្គភាព មកវិញទាំងអង្គភាពដដែលអត់មានឲ្យបាត់ទេ ។

ឈុនលី ៖ ប៉ុន្មាននាក់ ម៉ាអង្គភាព?

ថេង ៖ អង្គភាពវាច្រើនដែរ អង្គភាពវាមានយើងរៀបចំខាងនោះដូចខាងបងខាងសាធារណការពីដើម បងខាងនោះខាងឃ្លាំងគ្រប់គ្រងខាងឃ្លាំងម៉ាអង្គភាពទៅ មន្ទីរពេទ្យនោះម៉ាអង្គភាពទៅ ហើយខាងផ្នែកដឹកជញ្ជូនម៉ាអង្គភាពទៅ ហើយខាងផ្នែកទ័ពម៉ាអង្គភាពទៅ ចឹងវាចែកជាអង្គភាពៗ ។ ហើយទ័ពវាមានអង្គភាពច្រើនទៀត វាមាន១០៦ ១០៧ ១០៨ ១០៩ អង្គភាពវាមួយម៉ាវរៈនឹង ។ ក្នុងមួយវរៈបើគិតមើលទៅម៉ាវរសេនាធំ១០០០នាក់ដែរ វាច្រើនដែរ ។

ឈុនលី ៖ រាប់ម៉ឺនចឹង?

ថេង ៖ រាប់ម៉ឺនមិនតិចទេ ។

ឈុនលី ៖ ច្រើនមែនទែន?

ថេង ៖ យើងគិតថាប្រជាជនយើង ចាប់ពីកោះកុងរហូតដល់ស្រែណ្ដៅព្រំប្រទល់ឡាវ ហ្នឹងសុទ្ធកម្លាំងតស៊ូ ។ ហ្នឹងប្រជាជនយើងរាប់សែននាក់ វាបើកងទ័ព យើងមិនចាំបាច់និយាយប្រជាជនទេ និយាយកងទ័ព២១កងពល ។ វានៅប៉ុន្មាន...ច្រើនណាស់អ្នកតស៊ូមិនតិចទេបើនិយាយទៅ ។

ឈុនលី ៖ ចឹងពូដល់ពេលមកវិញ ពូធ្វើដូចរបៀបកងទ័ពធម្មតាដែរ?

ថេង ៖ បាទ! កងទ័ពធម្មតា ។

ឈុនលី ៖ ចុះអ្នកណាគេអ្នកគ្រប់គ្រងអង្គភាពហ្នឹងវិញ?

ថេង ៖ ដដែលនឹង ។

ឈុនលី ៖ ឈ្មោះ ឈឹម មុនីនឹង?

ថេង ៖ បាទ! គាត់ថ្នាក់តំបន់ដដែល ។

ឈុនលី ៖ ថ្នាក់តំបន់មកវិញដដែល ហើយអង្គភាពនឹងគេអ្នកចែកដីឲ្យប្រជាជនអីនៅ?

ថេង ៖ បាទ! យើងចែកតាមអង្គភាពៗ នៅម្ដុំនេះៗ ។

ឈុនលី ៖ ហើយចឹងបើដីសុទ្ធតែមីនចឹង ធ្វើម៉េចទៅ អ្នកណាដោះមីនឲ្យ?

ថេង ៖ ទ័ពកាលនោះសុទ្ធបច្ចេកទេសខាងដោះមីន... ។

ឈុនលី ៖ ព្រោះយើងធ្លាប់ដាក់តាំងពីមុននឹង?

ថេង ៖ ម្ដុំនេះ និយាយរួមទៅខាងស៊ីម៉ាក់មកដោះតិចណាស់ ភាគច្រើនគឺយើង ។

ឈុនលី ៖ ឆ្នាំណាដែលស៊ីម៉ាក់មក?

ថេង ៖ ស៊ីម៉ាក់មកក្រោយទេ ស៊ីម៉ាក់ទើបយើងធ្វើសមាហរណកម្មហើយ ទើបសម្រេចចូលមកដូច ៩៦ ៩៧ហ្នឹង ។ យើង៩៦យើងផ្ដាច់ខ្លួន សមាហរណកម្ម៩៦ ៩៧បានស៊ីម៉ាក់ចូលមកនឹង ស៊ីម៉ាក់ចូលមកនឹងមកដោះនៅកន្លែងដូចផ្លូវយើងមក១០២ តាមផ្លូវនឹងអត់ទាន់មានប្រជាជននៅទេ ប៉ុនស៊ីម៉ាក់មកដោះតាម... បើថាតំបន់នេះអត់ចាត់ការ រាវខ្លួនឯង ។

ឈុនលី ៖ ចឹងបានអ្នកខ្លះរាវទៅប៉ះផ្ទុះ?

ថេង ៖ បាទ! ស្លាប់ដោយសារមីនច្រើន ។

ឈុនលី ៖ ប៉ុន្តែពេលមកនឹងមានសង្គ្រាមទៀតទេ?

ថេង ៖ មកនឹង វ៉ៃគ្នាបានមើលបាន៥ឆ្នាំដែរ ។

ឈុនលី ៖ មកនឹងវ៉ៃគ្នាបាន៥ឆ្នាំទៀត?

ថេង ៖ បាទ!

ឈុនលី ៖ ពីឆ្នាំណា?

ថេង ៖ ពី៩០មកដល់ ។

ឈុនលី ៖ ៩០ដល់៩៥?

ថេង ៖ ៩៦ បានយើងធ្វើ ។

ឈុនលី ៖ ចូលសមាហរណកម្ម?

ថេង ៖ ហ្នឹងចូលគ្នា ។

ឈុនលី ៖ ហ្នឹងច្បាំងជាមួយខាងរដ្ឋកម្ពុជា?

ថេង ៖ បាទ!

ឈុនលី ៖ វៃគ្នាខ្លាំងទេ?

ថេង ៖ ខ្លាំង ក្នុងសង្គ្រាម ។

ឈុនលី ៖ ដូចស្រីៗ ចុះពូមានគ្រួសារនៅណាវិញ?

ថេង ៖ គ្រួសារនៅស្រុកកំណើត?

ឈុនលី ៖ អត់ទេ ដូចថារៀបការជាមួយគ្នាតាំងពីពេលណា?

ថេង ៖ អឺ! តាំងពីឆ្នាំ៨១ ។

ឈុនលី ៖ ពេលនៅនឹងដំបូងអត់ទាន់ទៅថៃ?

ថេង ៖ បាទ! តាំងពីជាមួយបងនៅនោះ នៅខាងដងរ៉ែក ។

ឈុនលី ៖ ចុះដូចខាងទ័ពទៅច្បាំងទៅ ស្រីៗនៅផ្ទះ?

ថេង ៖ គាត់នៅក្រោយ ។

ឈុនលី ៖ ចឹងគ្រួសារពូដឹកជញ្ជូនដែរអត់?

ថេង ៖ បាទ!កាលគាត់នៅលីវដឹកជញ្ជូន ដល់គាត់បានគ្រួសារទៅគាត់មកនៅផ្ទះយើងប្តីប្រពន្ធធម្មតា

ឈុនលី ៖ ប៉ុន្តែដល់ពេលពូទៅច្បាំងខ្ទង់៩០ជាង?

ថេង ៖ គាត់នៅផ្ទះមើលកូនមើលចៅនៅផ្ទះ ។

ឈុនលី ៖ អត់មានទៅណា?

ថេង ៖ អត់ទេ ។

ឈុនលី ៖ ភាគច្រើនចឹង?

ថេង ៖ តែមានគ្រួសារហើយលែងទៅ ។

ឈុនលី ៖ ភាគច្រើនចឹង?

ថេង ៖ បាទ!

ឈុនលី ៖ ដល់ពេលក្រោយចូលសមាហរណកម្មនឹងនោះ ពេលមុននឹងចូលនឹង សភាពការណ៍កាន់តែខ្លាំង ថែមហើយយ៉ាងម៉េច?

ថេង ៖ ដើរហ្នឹងហើយ ដែលយើងឆ្នាំ រឿងឆ្នាំ៩៣ ៩៤ ៩៥ ។

ឈុនលី ៖ បោះឆ្នោតហើយ ៩៤?

ថេង ៖ បាទ!៩៥បាញ់គ្នាខ្លាំង ៩៥វ៉ៃគ្នាខ្លាំងមែនទែន វាខុសគ្នាម៉េច ខ្លាំងម៉េច ។ ហ្នឹងគេទៅមើលវ៉ៃឲ្យខ្ទេចម៉ង ។

ឈុនលី ៖ ហើយយើងខំប្រឹងប្រយុទ្ធដែរ?

ថេង ៖ បាទ! ខំប្រយុទ្ធ ខំទប់ដែរ ប៉ុន្តែល្អដែរ អ្នកដឹកនាំម៉ាចំនួនឃើញការធ្វើសង្គ្រាមវាមិនអាចឃើញថាអ្នកណាឈ្នះ ហើយក៏មិនអាចអ្នកណាចាញ់ដែរ កាន់តែដំហើចកាន់តែហិនហោចវាកាន់តែ...ច្រើន និយាយរួមខាង....សម្រាប់ប្រទេសខ្មែរយើង ។ ចឹងក៏ទំនាក់ទំនងគ្នាថាយើងឈប់ច្បាំងទៅ ។

ឈុនលី ៖ ចឹងកាលនឹងអ្នកណាគេដូចថាដឹកនាំចរចា?

ថេង ៖ ហ្នឹងលោកអ៊ំអៀង សារី និយាយឲ្យចំ ។

ឈុនលី ៖ ព្រោះគាត់អ្នកគ្រប់គ្រង?

ថេង ៖ អ៊ំអៀង សារី គាត់មានកូនចៅដែលចប់នៅនេះ គឺលោកសុខ ភាព១ ប៉ុនគ្រាន់ថាគាត់ទំនាក់ទំនងជាអ៊ំ អៀង សារីចឹងទៅ ។ ខាងលោកសុខ ភាពនឹងគាត់បង្កើតសេវាមួយ ដើម្បីទំនាក់ទំនងជាមួយខាងរដ្ឋកម្ពុជា ជាពិសេសសម្តេចនាយករដ្ឋមន្ត្រីហ៊ុនសែន រាល់ថ្ងៃនេះ ។ ចឹងទៅគាត់ទប់ស្កាត់ខាងអ្នកដែលគេមិនដឹង មានអ្នកខ្លះគេមិនទាន់ដឹងថាយើងធ្វើយ៉ាងម៉េច១ទេ គេប្រុងនឹងវ៉ៃយើងដែរនឹង ដូចថាអ្នកទៅសួរដូចគ្នានឹង ។ តែខាងប៉ៃលិន នឹងម៉ាឡៃនេះ ទំនាក់ទំនងខាងសម្តេចនឹងទៅ ។ បាននៅឆ្នាំ៩៦ យើង ។

ឈុនលី ៖ ផ្តាច់ខ្លួនចូលគ្នាបណ្តោយ?

ថេង ៖ ជួបគ្នាបណ្តោយ ។

ឈុនលី ៖ ចឹងកាលនឹងមានតែស្រុកម៉ាឡៃ ហើយជាមួយប៉ៃលិនចឹងមកជុំគ្នា?

ថេង ៖ បាទ! មុនដំបូងគឺម៉ាឡៃនឹងឯង ហើយបានបន្ទាប់មកប៉ៃលិនបាន លោកអ៊ី ឈាន និងលោកសុខ ភាព គាត់ទំនាក់ទំនងគ្នាចឹងទៅ គាត់ចិត្តដូចគ្នា ។

ឈុនលី ៖ លោកអ៊ី ឈាន គាត់មានឋានៈស្មើគ្នាជាមួយលោកសុខ ភាពនឹង?

ថេង ៖ បាទ!

ឈុនលី ៖ គ្រាន់ថាម្នាងគាត់កាន់ខាងម៉ាឡៃ ម្នាងទៀត?

ថេង ៖ បាទ! ខាងនោះគេហៅកងពលធំ ។

ឈុនលី ៖ លេខប៉ុន្មាន មានលេខមានអី?

ថេង ៖ លេខកងពលធំនឹងវាលេខ១៥០ ដឹកនាំដោយលោកសុខ ភាព ហើយលោកអ៊ី ឈាន កងពលប៉ុន្មានបងឈាន ។ ហ្នឹងថា៥០ដាង ប៉ុនដូចថាមិនដឹងទេ ខាងអ៊ី ឈាន ។

ឈុនលី ៖ គ្រាន់ខាងយើងដឹងឈ្មោះ ។

ថេង ៖ ប៉ៃលិន ។

ឈុនលី ៖ ចុះដល់ពេលក្រោយសមាហរណកម្មចឹង ពូនៅធ្វើទ័ពទៀតអត់?

ថេង ៖ បាទ! កាលនឹងព្រោះថាពាក្យសមាហរណកម្ម គឺថាចូលរួមៗជាមួយ......ហើយក៏គ្មានអ្នកឈ្នះអ្នកណាចាញ់ ។

ឈុនលី ៖ និយាយទៅរួបរួមគ្នា?

ថេង ៖ បាទ! អ្នកណាដែលមានតួនាទីអី គឺកាន់តួនាទីនឹងដដែល ពាក្យនឹងគឺចឹង ហើយគឺយើងរស់នៅដោយការបង្កើតរបស់រដ្ឋាភិបាលយ៉ាងម៉េច គឺធ្វើតាមនឹង ។ ចឹងស្រុកម៉ាឡៃយើងវាកើតជាកងទ័ព២ផ្នែក មួយខាងកងពល មួយខាងសឹករង ។ សឹករងយើងហៅកងទ័ពស្រុក ។ ចឹងយើងធ្វើជាកងទ័ពស្រុកតាមផែនការរបស់រដ្ឋាភិបាល ។

ឈុនលី ៖ ពូខាងកងទ័ពស្រុក?

ថេង ៖ បាទ! ប៉ុនឥឡូវនេះដាច់ហើយ ឥឡូវនេះពួកខ្ញុំពិការ ចឹងចូលរំសាយហៅទ័ពរំសាយហើយ ។ រស់នៅជាប្រជាជនសាមញ្ញធម្មតា ។

ឈុនលី ៖ ចឹងពូកាន់កងស្រុកនឹង ពូអ្នកកាន់?

ថេង ៖ អត់ទេ នៅប្រជាជនផ្សេង ។

ឈុនលី ៖ អ្នកណាគេអ្នកកាប់ខាងនឹង?

ថេង ៖ លោកជា ជឿន ។

ឈុនលី ៖ អានឹងពេលផ្តាច់ខ្លួនដែរ ៩៦ដែរ?

ថេង ៖ បាទ! លោក ជា ជឿន មេបញ្ជាការសឹករងស្រុក ។

ឈុនលី ៖ ពេលនឹងគេបង្កើតជាស្រុក?

ថេង ៖ បាទ! បង្កើតជាកងទ័ពស្រុក ហើយបានដាក់ស្រុកម៉ាឡៃ ។

ឈុនលី ៖ ហើយគេបែងចែងភូមិ ឃុំ តាមក្រោយទៀត?

ថេង ៖ បាទ!

ឈុនលី ៖ ហើយពូក៏រស់នៅ?

ថេង ៖ ខ្ញុំនៅភូមិកណ្ដាល ។

ឈុនលី ៖ រស់នៅតាំងពីនឹងរហូតមកដល់ឥឡូវ?

ថេង ៖ បាទ!

ឈុនលី ៖ ចុះដល់ពេលឆ្នាំណាដែលពួលឈប់ធ្វើនេះ ពួពិការដើងឆ្នាំណា?

ថេង ៖ ខ្ញុំពិការតាំងពីឆ្នាំ៨៨ ១៩៨៨ ។

ឈុនលី ៖ អានឹងនៅថៃនឹង?

ថេង ៖ បាទ! កាលនឹងខ្ញុំនៅថៃ ។

ឈុនលី ៖ ម៉េចបានពិការចឹង?

ថេង ៖ យើងចូល១វ៉ៃដែរ ។

ឈុនលី ៖ ចឹងបានន័យថាទៅថៃនឹង គេឲ្យយើងចេញចូល?

ថេង ៖ បាទ! យើងនៅថៃមែន កន្លែងនឹងជំរំកងទ័ព ប៉ុន្តែយើងត្រូវតែចូលទៅវ៉ៃក្នុង ។

ឈុនលី ៖ ប៉ុន្តែយើងធ្វើអត់ទាន់បានដដែល?

អ្នកជិតខាង ៖ ធ្វើមិនទាន់បានទេ ។

ឈុនលី ៖ ចឹងយើងវ៉ៃហើយយើងចូលទៅនឹងវិញ?

អ្នកជិតខាង៖ អឺ! វ៉ៃចេញចូលទៅដីថៃ ។

ឈុនលី ៖ ដូចផ្ទះយើងនៅ?

ថេង ៖ បាទ! កាលនោះចេះ ដូចនៅជំរំ១-៨៥នឹង គឺយើងសំខាន់នៅតែអ្នកឃ្លាំងទេ ដូចខាងបង អ្នកឃ្លាំង ហើយនឹងគ្រួសារនៅនឹង ។ បើកងទ័ពនៅក្នុងទាំងអស់ វ៉ៃក្នុងព្រំដែនអត់មាន ប៉ុន កម្លាំងវ៉ៃ ។

អ្នកជិតខាង ៖ ប៉ុនវា សម្ភារៈគ្រាប់អីនៅនោះ ដល់ពេលវ៉ៃទៅវាដឹកជញ្ជូនទ័ពចេញទៅឲ្យទ័ពនៅក្នុង នោះ ។

ឈុនលី ៖ ពួលឈប់ធ្វើទ័ពនឹងឆ្នាំណា?

ថេង ៖ គេកាត់រំសាយខ្ទង់ប៉ុនណា ២០០០ជាង ។

អ្នកជិតខាង ៖ យើងទៅកាត់ប៉ុន្មានឆ្នាំហើយ យើងទៅកាត់ ។

ថេង ៖ ហ្នឹងហើយ ប៉ុនគ្រាន់ថានិយាយរួមទៅយើងនៅប្រើប្រាក់គោលនយោបាយរបស់ទ័ពដដែល តាមរយៈទាហាន ។ ប៉ុនទើបឆ្នាំ២០០៨ ២០០៩បានយើងកាត់រំសាយចេញពីនែក!

ឈុនលី ៖ ទើបថ្មី១ដែរ?

ថេង ៖ បាទ! អានឹងយើងលែងទទួលគោលនយោបាយពីទ័ពហើយណា អត់មានទេ ។

អ្នកជិតខាង ៖ អានឹងចូលមកដល់សន្តមកិច្ច ។

ថេង ៖ បាទ! ចឹងមករាល់ថ្ងៃនេះ យើងប្រើប្រាស់ប្រាក់ខែខាងសន្តមកិច្ចវិញ ទទួលបានពីសន្តម ។

ឈុនលី ៖ ចឹងពូទើបនឹងឈប់ដែរ?

ថេង ៖ បាទ!

ឈុនលី ៖ ខ្ទង់ខែណា ២០០៩?

ថេង ៖ ២០០៩ ខែ១ ។

ឈុនលី ៖ តាំងពីដើមឆ្នាំ?

ថេង ៖ បាទ! កាលពិតទៅដែនការគេកាត់យូរហើយ ប៉ុន្តែគ្រាន់ថាកាលនោះលុយវាមិនទាន់មាន ចឹងគេទុកៗបើកជាមួយទ័ព ។ បើយើងមិនធ្វើអីយើងមិនទៅបន្ទាយអីទេ យើងនៅផ្ទះ បើយើងពិការហើយ ប៉ុន្តែគ្រាន់ថាយើងទទួលបៀវត្សរ៍តាមរយៈកងទ័ពនឹង ទម្រាំគេមានលុយសន្តមកិច្ចនឹង បានគេបញ្ជូនសន្តមកិច្ចមក ។ ប៉ុន្តែវាមានច្រើនជំហាន វាមានជំហានសាកល្បង ម៉ាវគ្គទៅ ជំហានទី១ ១វគ្គទៅ ជំហានទី២បានពួកខ្ញុំ ។

ឈុនលី ៖ ចុះដូចពូពេលក្រោយពីកាត់បន្ទាយទ័ពចឹង ពូរស់នៅនឹងធម្មតា ពូធ្វើការងារអី?

ថេង ៖ បាទ! នៅជាប្រជាពលរដ្ឋធម្មតា អត់ទេ ។

ឈុនលី ៖ ដាំចំការដាំអី?

ថេង ៖ ខ្ញុំមានដែរ មានចំការតូចៗ ។

ឈុនលី ៖ ចំការសណ្តែកចំការអីនឹង?

ថេង ៖ បាទ!

ឈុនលី ៖ ចឹងរហូតមកដល់ឥឡូវពូមានកូនប៉ុន្មាននាក់?

ថេង ៖ ៤ ។

ឈុនលី ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ថេង ៖ ប្រុស១ ស្រី៣ ។

ឈុនលី ៖ បានរៀនសូត្រច្រើនដែរ?

ថេង ៖ វាបងគេរៀនបានតិច រៀនបានថ្នាក់ទី៧ បន្ទាប់មកប្រុសបានបាក់ឌុប បន្ទាប់មកទៀតនោះបានឌីប្លូម ហើយពៅគេនោះជិតប្រឡងឌីប្លូម ។

ឈុនលី ៖ ថ្នាក់ទី៨ ៩?

ថេង ៖ បាទ!

ឈុនលី ៖ ហើយពូដែលទៅលេងស្រុកកំណើតវិញដែរ?

ថេង ៈ ទៅ ។

ឈុនលី ៈ ទៅញឹក?

ថេង ៈ បាទ! មិនសូវញឹកប៉ុន្មាន ។

ឈុនលី ៈ ទៅខែបុណ្យទាន?

ថេង ៈ ជួនកាលបុណ្យទានអត់សូវយើងបានទៅទេ អាពេលណាយើងទំនេរខ្ញុំទៅ ទៅបានប្រហែលជា ៥ដង ៦ដង ។

ឈុនលី ៈ ចុះដូចពូបែកពីស្រុកកំណើតយូរហើយ ដល់ពេលទៅលេងវិញដូចមានអារម្មណ៍ម៉េច?

ថេង ៈ អានឹងធម្មតាទេ ប៉ុន្តែគ្រាន់ថាយើងការកាត់ចិត្តរបស់យើង យើងមិនធ្លាប់បែកពីឥឡូវទេ យើងបែកតាំងពីដើម តាំងពីយូរមកសង្គ្រាមវៃអាមេរិចកាំង ដល់យើងសង្គ្រាមបែកយូរនេះ យើងរវាងយើងជាមួយវៀតណាម ដែលយើងយូរ៣០ឆ្នាំបានៗទៅនោះ បានយើងបានទៅលេង ។

ឈុនលី ៈ ចុះដល់ពេលទៅដល់ ពួកគាត់មានភ្ញាក់ផ្អើលបងប្អូន?

ថេង ៈ ការពិតទៅគាត់ដឹងៗដំណឹងយើងមុនទៅហើយ ប្រហែលជា៧ឆ្នាំទៅហើយ តាំងខ្ញុំនៅនេះ ។

ឈុនលី ៈ ខ្ទង់២០០០ជាង ខ្ទង់ប៉ុន្មាន?

ថេង ៈ គាត់ដឹងតាំងពី៨០ជាង ។

ឈុនលី ៈ គាត់ហៅទៅវិញ?

ថេង ៈ ទេ! គាត់ហៅដែរ ។

ឈុនលី ៈ តែម៉េចពូអត់ទៅ?

ថេង ៈ ព្រោះនេះធម្មតាទេ យើងនៅនេះយើងចង់ដឹងលទ្ធផលចុងក្រោយវាយ៉ាងម៉េចៗ ។

ឈុនលី ៈ ព្រោះខំតស៊ូយូរមកហើយ?

ថេង ៈ បាទ! ហើយម្យ៉ាងយើងម្នាក់ៗយើងថាយើងជាអ្នកស្នេហាជាតិ មិនចឹង ទាំងអស់គ្នាអ្នកស្នេហាជាតិ អ៊ីដែលថាគេចូលមកទន្ទ្រាននៅស្រុកយើង ដែលយើងសុខចិត្តចុះញមគេ អានេះក្ខុយឯង បើសិនគេមកទន្ទ្រានលើក្រុមគ្រួសារយើងដែលសុខចិត្ត យើងត្រូវតស៊ូ ។ កាលនោះយើងមិនដឹងថាវាវិវត្តន៍ដល់ម្ល៉ឹងថាចឹង ។ ដល់កាលនោះយើងសន្និបាតកំពូលនៅប្រទេសបារាំង ២៣តុលាឆ្នាំ១៩៩១ ដែលយើងឲ្យយួនចេញពីកម្ពុជាចឹង ដកចេញពីកម្ពុជាដើម្បីឲ្យខ្មែរយើងរួបរួមគ្នាវិញ ។ ដល់ចឹងទៅយួនគេចាប់ផ្ដើមដកៗទៅ ដល់យើងនៅឆ្នាំ៩៣ យើងបង្កើតអាថ្ងៃ២៣តុលា ។

ឈុនលី ៈ កិច្ចព្រមព្រៀងទីក្រុងបារីស?

ថេង ៖ បាទ! ឲ្យមានអ៊ុនគាត់ចុះមក ការពិតទៅកាលនោះអត់មានអន្តការកណ្តាលមកគេនិយាយពីរឿងប៉ុលពតទេ ។ អាថ្ងៃ២៣តុលា គឺប៉ុលពតអ្នកបង្កើតកាលនឹង ប៉ុលពតផ្ទាល់អ្នកបង្កើត បើគ្មានបង្កើតទេ ថ្ងៃ២៣តុលានឹង ក៏អ៊ុនគាត់គ្មានមកដែរ ។ ២៣តុលា បានអ៊ុនគាត់ចូលមករៀបចំប្រទេសកម្ពុជាយើង ឲ្យទៅជាប្រទេសខ្មែរ ឲ្យវាទៅមានខ្មែរអំណាចឃុំភូមិខ្មែរសុទ្ធ បានធ្វើការបោះឆ្នោតក្រោមអ៊ុនគាត់ ហើយបានគេទាមទារឲ្យយើងចូលរួមបោះឆ្នោតដែរ ។ ប៉ុនតែកាលនោះដោយសារមានអ្នកដឹកនាំម៉ាចំនួន ដែលប្រឆាំងមិនឲ្យយើងចូលបោះឆ្នោត ។

ឈុនលី ៖ អ្នកណាគេទៅ?

ថេង ៖ ប៉ុនឥឡូវងាប់បាត់ហើយ ស៊ុន សេន ។

ឈុនលី ៖ គាត់អត់ឲ្យចូល?

ថេង ៖ អត់ឲ្យចូល ប៉ុនទស្សនៈប៉ុលពត ទស្សនៈខៀវ សំផន ទស្សនៈអៀង សារី គាត់ឲ្យចូល ហើយទស្សនៈអ៊ំនួន ជា ឲ្យចូលបោះឆ្នោតទៅ ព្រោះយើងមិនមែនសង្ឃឹមថាឈ្នះ គឺចាញ់ ប៉ុន្តែចាញ់ក៏វាមានឈ្មោះក្នុងរដ្ឋសភាពដែរ ។ យើងមានឈ្មោះបោះឆ្នោតម៉ាអាណត្តិដែរ ។ ប៉ុនដល់ពេលហើយចាញ់បោកស៊ុន សេន មិនឲ្យចូល ។ ដល់ចឹងសង្គ្រាមយើងចេះវារាំងរ៉ៃតិចណា ព្រោះគាត់យល់ឃើញចេះ ប៉ុលពតយល់ឃើញថាបើសិនយើងមិនអ្នកឲ្យអ៊ុនគាត់ចូលទេ វាចេះសង្គ្រាមរាំរ៉ៃ ។ កើតលីប៉ង់កម្ពុជា ប្រទេសលីបង់គឺអស់ហើយ រលាយ បើកាលណាបើសិនយើងរ៉ៃឈ្នះ ក៏ភាគីប៉ុន្មានទនឹងគេមិនពេញចិត្តនឹង ចេញទៅនោះ មិនរ៉ៃតទៅទៀតៗ ប្រទេសខ្មែរយើងរាំរ៉ៃៗទន់ដៃទន់ជើង គេមកម៉ាក្រឹបទៀតអស់រលីង ចឹងក៏សុខចិត្តមានថ្ងៃ២៣តុលានេះ ឲ្យខ្មែរមាន៤ភាគីនេះ វាទៅជាត្រីភាគីទៅរួបរួមគ្នាវិញទៅ ហ្នឹងទស្សនៈគាត់ ប៉ុន្តែមិនដល់ ។

ឈុនលី ៖ ៤ភាគី ហើយនៅសល់តែ៣ភាគីវិញ ដោយសារតែស៊ុន សេនអត់ឲ្យចូលរួម?

ថេង ៖ បាទ! កាលនោះវាមានខាងរដ្ឋកម្ពុជា១ សឺន សាន២ ហើយខាងសម្តេចសីហនុ៣ ហើយយើង៤ ហៅ៤ភាគីចូលគ្នាទៅជាត្រីភាគី ។

ឈុនលី ៖ ចឹងបានន័យថាយើងទៅជាក្រុមប្រឆាំងនឹងគេវិញ ដល់ពេលយើងអត់ចូល?

ថេង ៖ បាទ! យើងអត់ចូល គេដាក់ក្រៅច្បាប់ ប៉ុនដល់ដូចខ្ញុំបញ្ជាក់ខាងលើដោយសារមានអៀង សារី គាត់ជំហរមួយ ហើយដល់ខាងនោះស៊ុន សេន មុននឹងស្លាប់នេះ មកធ្វើបាបនៅស្រុកម៉ាឡៃសំបើមណាស់ ។

ឈុនលី ៖ ធ្វើបាបម៉េចខ្លះ?

ថេង ៖ ដោយសារ ដកហូតនៅទ្រព្យសម្បត្តិផ្ទាល់ខ្លួន គេចង់ឲ្យយើងធ្វើដំណើរការពីដើមមក ថាឆ្នាំង មួយទាំងអស់គ្នា ។

ឈុនលី ៖ រួមទៀតហើយ?

ថេង ៖ រួមទៀត ។

ឈុនលី ៖ អានឹងឆ្នាំណាទៅ ដក?

ថេង ៖ ឆ្នាំ៩៨ ៩៩ មកដករទេះគោ ដកឡាន ដកអីពីបងប្អូនយើង ។

អ្នកជិតខាង ៖ ចឹងបានម៉ាឡៃដាក់រទេះគោនៅរង្វង់មូលតំណាង កាលនឹងជំនាន់នឹងដករទេះគោនឹងបាន ប្រជាជនប៉ះបោរឡើងប្រឆាំងវិញ ។

ឈុនលី ៖ តំណាងអីគេ?

អ្នកជិតខាង ៖ តំណាងដែលគេដករទេះគោពីប្រជាជនដែលទៅរកស៊ី ។

ថេង ៖ បាទ! ប្រជាជនយើងមានរទេះ មានគោ ដែលសម្រាប់យកមកប្រើប្រាស់ រកស៊ី ។

អ្នកជិតខាង ៖ ចុះប្រជាជនពីដើម ពីសង្គម ពីដូនតាមកវារស់ដោយសាររទេះមានគោ មានក្របីដែល ភ្ជួររាស់ ដល់ពេលគេមកធ្វើចឹងដកតាំងពីអាត្រាក់ទ័រឡាន ដល់ពេលឈានដល់ដករទេះគោ គេប៉ះបោរបណ្តោយ ។ ប៉ះបោរផ្តាច់ខ្លួនបណ្តោយ ។

ថេង ៖ ហើយស៊ុន សេននឹង ក៏យើងមិនដឹងថាគាត់ជាកម្លាំងខាងណាដែរ ប៉ុនគ្រាន់ថាប៉ុលពតដឹងថា ស៊ុន សេននេះបំផ្លាញខ្មែរយើងតាំងពីឆ្នាំ១៩៧៥ ដែលយើងរំដោះភ្នំពេញ ហើយគាត់ នោះឯង ជាអ្នកសម្លាប់ប្រជាជនផ្ទាល់ ។

ឈុនលី ៖ ស៊ុន សេន?

ថេង ៖ បាទ!

ឈុនលី ៖ បានន័យថាស៊ុន សេន ក្បត់ប៉ុលពត ហើយប៉ុលពតទើបនឹងដឹងក្រោយ?

ថេង ៖ ក្បត់ហ្នឹងអ្នកតស៊ូ បាទ! ព្រោះប៉ុលពត អ៊ំខៀវ សំផន ជាអ្នកតស៊ូ ជាអ្នកស្នេហាជាតិពិត ប្រាកដ តែស៊ុន សេនទេ ជាអ្នកសម្លាប់ ។ កាលនោះពេលគាត់ស្លាប់ហើយមិនដឹងណាយក គាត់មកកាត់ទោស ។

ឈុនលី ៖ ....ប៉ះបោរនាំគ្នាផ្តាច់ខ្លួនទៅ?

ថេង ៖ បាទ! ដល់ចឹងទៅបានអ៊ំ អៀង សារី ឃើញស្ថានភាពនឹងវាមិនអាចយកឈ្នះចាញ់បាន ហើយម្យ៉ាងទៀតយើងឃើញថាភាគច្រើន គឺខ្មែរនិងខ្មែរវៃគ្នាបងប្អូនគាត់ក៏មាន ខ្ញុំក៏មានបង ប្អូនខាងនោះវៃគ្នាឯង ដល់ចឹងទៅតាមរយៈលោកសុខ ភាពរាល់ថ្ងៃនេះ ។ លោកសុខ ភាព គាត់ជាទីប្រឹក្សាផ្ទាល់របស់សម្តេចនាយករាល់ថ្ងៃហើយនឹងលោកអ៊ី ឈាន ។

ឈុនលី ៖ ខាងប៉ៃលិន?

ថេង ៖ បាទ!

អ្នកជិតខាង ៖ កុំអីទុកត្រៀមកម្លាំងវ៉ៃគ្នា ជីកត្រង់សេររៀងខ្លួន ខាងតាកន ហើយនឹងខាងម៉ាឡៃ ។

ឈុនលី ៖ ខាងតាកនៗខាងណា?

ថេង ៖ តាកនខាង៣២ តំបន់ផ្សេង ។

អ្នកជិតខាង ៖ ស៊ុន សេន ខាងស៊ុន សេន ខាង៣២នឹង ។

ថេង ៖ តាកននឹងគាត់ប្អូនស៊ុន សេន ។

ឈុនលី ៖ ប្អូនបង្កើត?

ថេង ៖ បាទ!

អ្នកជិតខាង ៖ ត្រៀមជីកត្រង់សេរដាក់ទល់មុខគ្នាហើយនឹង ។

ឈុនលី ៖ ដល់ពេលនឹងដូចរបៀបថាអ្នកតស៊ូដូចគ្នាប៉ុន្តែទៅជាសង្គ្រាមផ្ទៃក្នុង?

ថេង ៖ បាទ! ដល់ចឹងបានលោកសុខ ភាពនេះតាមរយៈលោកអ៊ំអៀង សារីៗ អ្នកដឹកនាំហើយ តាមរយៈលោកសុខ ភាព លោកអ៊ី ឈាននឹង បង្កើតចលនាផ្តាច់ខ្លួន ថាបង្កើតចលនាផ្តាច់ខ្លួនមុន ទំនាក់ទំនងខាងសម្តេចខាងរដ្ឋាភិបាល ។ កាលនោះយើងទំនាក់ទំនងខាងសម្តេចផ្ទាល់តែម៉ង យើងចាត់ចែងទៅចូលរួមផ្សះផ្សាគ្នាទៅ ។

ឈុនលី ៖ ពូថាទៅដករទេះកាលនឹង៩០ប៉ុន្មាន?

ថេង ៖ ៩៤ ៩៥ ដក ។

អ្នកជិតខាង ៖ ទេ យើងផ្តាច់៩៦ ៩៧ ។

ថេង ៖ យើង៩៦ ។

ឈុនលី ៖ ខែណាពូចាំទេ?

ថេង ៖ កាលសម្តេចហ៊ុន សែន ខែ៩ ថ្ងៃ១៥ខែ៩ ។

ឈុនលី ៖ ថ្ងៃ១៥ ខែ៩?

ថេង ៖ ថ្ងៃ១៥ ខែ៩ បាទ! ។

អ្នកជិតខាង ៖ មុនដំបូងដកឡានដកអីប្រជាជនអត់ទាន់ប៉ះបោរទេ តែពេលដករទេះគោដករបស់កសិករហើយ ។

ឈុនលី ៖ អានឹងដូចរបៀបថា ចុះម៉េចបានប្រជាជនគាត់ប៉ះបោរ ព្រោះពីមុនមក៧៥-៧៩ គាត់នៅរបៀបសហករណ៍ដែរ ហេតុអីបានដក ដើម្បីដាក់របស់រួម ប៉ុន្តែគាត់ទៅជាប៉ះបោរវិញ?

ថេង ៖ បាទ! យើងកាលនោះ រត់ចេញពីភ្នំពេញ រត់ចេញពីមូលដ្ឋានដោយសារអី ដោយសារអាឆ្នាំងមួយនឹងឯង ។ បើគាត់ចង់ទៅអាឆ្នាំងមួយអ្នកណាសុខចិត្ត ។

ឈុនលី ៖ គាត់គិតថាពិបាកចឹង?

ថេង ៖ បាទ! យើងដឹងហើយតើ ប្រជាជនយើងកូនចៅយើងរកតែនំប៉័ងហូបមួយមិនបាន ។

អ្នកជិតខាង ៖ ដល់ពេលរត់មករស់នៅឯកជនគេស្រួល ដល់ចឹងគេចង់ទៅឆ្នាំងមួយវិញ ប្រជាជនប៉ះពោរ ។

ថេង ៖ កាលនោះបើសិនជាកុំមានយួន ខ្មែរយើងអត់មានអាមួយមកខាងលិច ៧៩ ។ បើសិនណាសង្គ្រាមផ្ទៃក្នុងវិញ សង្គ្រាមរវាងខ្មែរនិងខ្មែរ គ្មានខ្មែររត់ចេញទេ អត់មានទេ ។ ប៉ុនខ្លាំងគឺយួនម៉ងកាលនោះចូលមក ប៉ុនកាលនោះខាងរដ្ឋកម្ពុជាគេបង្កើតថារណសិរ្សសង្គ្រោះជាតិដូចសម្តេចនាយកគាត់លើក បើសិនគាត់មិនពឹងពាក់គេ មិនងាយចប់ទេ សង្គ្រាម អ្នកសម្លាប់ជំនាន់នោះ ។ គាត់តែងនិយាយធម្មតាទេ ក្រុមគ្រួសារតែមួយ បើទាស់ទែងគ្នាហើយ ឪពុកណែនាំកូននឹងក៏មិនស្តាប់ បងប្អូនគាៗទៀតណែនាំអាកូនមួយនឹងមិនស្តាប់ ត្រូវពឹងពាក់អ្នកជិតខាង ។ ចឹងគាត់ត្រូវពឹងពាក់អ្នកជិតខាង កាលនោះពឹងពាក់អ្នកជិតខាង ដើម្បីមកទប់ស្កាត់អាបញ្ហានឹងឲ្យបានសិន ហើយចាំដកចេញទៅវិញ អានឹងចឹង ។ ហើយកាលនោះខ្មែរនិងខ្មែរអត់មានរត់ចេញទេ ។

ឈុនលី ៖ ចឹងបានន័យថាប្រជាជនដែលគាត់រត់មកតាមនឹង គាត់ចង់ចូលជាមួយរដ្ឋាភិបាលដែរ?

ថេង ៖ បាទ! ទស្សនៈមិនទំនាស់គ្នាទេ រឿងខ្មែរនិងខ្មែរ អត់ទំនាស់សោះ ។

ឈុនលី ៖ តែអាស្រ័យអ្នកដឹកនាំ?

ថេង ៖ បាទ! គឺសំខាន់យើងឃើញច្បាស់ថាឥឡូវមិនមែនខ្មែរ គឺយួនមកទាំងកាប៉ាល់មកទាំងរថក្រោះមកទាំងអី ចឹងបាននាំគ្នាចេញមក បើមានសម្តេចរាល់ថ្ងៃមានអី ។

ឈុនលី ៖ យើងគិតថាមិនប្រជាជនយើងណា?

ថេង ៖ បាទ! យើងថាជារឿងឈ្លានពាន រឿងបរទេសឈ្លានពាន ។

ឈុនលី ៖ ដូចបងប្អូនពូនៅនោះ ដល់ពេលគាត់ដឹងពូនៅចូលជាមួយខ្មែរក្រហម គាត់ខឹង គាត់អីអត់?

ថេង ៖ គាត់អត់មានអី មានតែខឹងអី ប៉ុន្តែគ្រាន់តែថាគាត់មិនចង់ឲ្យយើងនៅក្រៅ មកនៅនឹងព្រៃ គាត់យល់ឃើញថា យើងតស៊ូនៅក្រៅយើងមិនអាចឈ្នះខាងក្នុងទេ នៅដល់ណាទៀត ។ ក៏ប៉ុន្តែការយល់របស់គាត់ក៏វាមិនត្រូវ១០០ភាគរយដែរ យើងគិតថាការរើអាមេរិចកាំងយើងនៅខាងក្រៅ ហេតុអីបានអាមេរិចកាំងវាចាញ់ កាលនោះដោយសារកម្លាំងប្រជាជន

យើងស្នេហាជាតិ អាមេរិចកាំងចង់គ្រប់គ្រងខ្មែរយើងទាំងស្រុងកាលនឹង ។ និយាយពីប្រវត្តិសាស្ត្រចិន វាពាក់ព័ន្ធច្រើន នឹកឃើញថាយើងតស៊ូមិនមែនចាញ់ទេ គឺឈ្នះ ។

ឈុនលី ៖ ចុះដល់ពេលក្រោយស្រុកយើងសន្តិភាពហើយ ពូគិតថាយើងចង់ផ្សះផ្សាជាមួយប្រជាជនដទៃ?

ថេង ៖ ទេ!

ឈុនលី ៖ របៀបថាយើងកាលលើកមុននៅបែកបាក់គ្នា ដល់ពេលក្រោយពូចង់ត្រូវគ្នាជាមួយគេ?

ថេង ៖ ឥឡូវជាទស្សនៈគោលជំហររបស់ពួកខាងខ្ញុំ ខ្ញុំថាបើខ្ញុំនិយាយ ខ្ញុំហ៊ានថាបើខ្ញុំនិយាយតែម្នាក់ឯង បងប្អូននៅនេះក៏ចិត្តដូចខ្ញុំ ។

ឈុនលី ៖ ចង់ត្រូវជាមួយគេជាមួយឯង?

ថេង ៖ បាទ! គឺយើងមិនចង់ឲ្យមានសង្គ្រាមតទៅទៀតទេ អត់ចង់មានទាល់តែសោះ ហើយទស្សនៈម្នាក់ៗទាំងអស់គ្នានេះ គឺថារកខ្មែរឲ្យពិតម៉ង់ តាំងពីកំពូលរហូតដល់បាត និយាយរួមអ្នកដឹកនាំឲ្យទៅជាខ្មែរ សម្តេចនាយកគាត់ខំបង្កើតតាំងពីក្រសួងវប្បធម៌ រាល់ថ្ងៃនេះមិនឲ្យយកវប្បធម៌បរទេសមកច្រលូកច្រឡំ មិនឲ្យយកស៊ីមកដាក់ខ្មែរយើងលំបាក បង្កើតជាល្ខោន បង្កើតជាយីកេ បង្កើតជាអាយ៉ៃ បង្កើតជាមហោរី អាចឹងជាគុណធម៌របស់គាត់ គាត់ចង់ឲ្យខ្មែរយើងស្គាល់ខ្មែរច្បាស់ ស្គាល់ធាតុខ្មែរយើងច្បាស់ពិតប្រាកដ មិនដូចថៃរាល់ថ្ងៃចោទថាខ្មែរយើងមិនមែនខ្មែរនៅនេះទេ មិនចឹង ។ ថាខ្មែរយើងច្រឡំប្រវត្តិសាស្ត្រ ការពិតហ្នឹងហើយវាតើ ។

ឈុនលី ៖ អ្នកបន្ទំ?

ថេង ៖ បាទ! វាបំភ្លៃប្រវត្តិសាស្ត្រ ព្រោះខ្ញុំរៀនពីប្រវត្តិសាស្ត្រ ខ្ញុំយល់ ខ្ញុំដឹងច្រើនពីប្រវត្តិសាស្ត្រថាខ្មែរយើងគឺពូជអំបូលនៅនឹង ។ ហើយប្រទេសខ្មែរយើងមិនមែនតូចទេពីដើមមក រាប់ម៉ឺនអឺ!រាប់លានម៉ែត្រការ៉េដី មិនមែនរាប់ម៉ឺន រាប់លានម៉ែត្រការ៉េដី មិនមែននៅរាល់ថ្ងៃនឹង ៨១ពាន់ម៉ែត្រការ៉េទេ ។ ចឹងថៃគ្មានដីណាតិចទេ នៅកោះណាមួយថៃដែលពួកនិយមរបស់ចិនមកនៅ ។ ថៃទើបមានឈ្មោះនៅសតវត្សរ៍ទី១៣ ហើយនៅក្រោយប្រាសាទព្រះវិហារដែលយើងបង្កើតនៅសតវត្សរ៍ទី១១ ហើយថៃទើបមានឈ្មោះនៅសតវត្សរ៍ទី១៣ ។

ឈុនលី ៖ ចុះយើងទៅជំរំចឹង គេធ្វើបាបយើងអត់?

ថេង ៖ អូ! មិនធ្វើបាបម៉េច យើងជាមែនទែនជាប្រជាជនរងគ្រោះទៅនៅប្រទេសគេ ប៉ុន្តែដោយសារអ្នកដឹកនាំយើងឈ្លាសវៃណាស់ កាលនោះគឺយើងសហការជាមួយអ្នកដឹកនាំថៃកំពូលៗ ថៃក៏គេមានអ្នកគោលជំហរល្អដែរ មិនមែនអត់ទេ យើងមានកម្លាំងតស៊ូចង់ប្រឆាំងនឹងពួកថៃ

ក៏មាន ។ ចឹងអ្នកដឹកនាំយើងទំនាក់លទំនងពេលនឹងឯង ដើម្បីឲ្យកម្លាំងគេនឹងមកការពារខ្មែរ យើងកុំឲ្យពួកអាថៃខ្លះធ្វើបាបណា ។ បើសិនគ្មានទេនឹង សូម្បីតែប្រជាជនថៃតូចមួយក៏ហ៊ានធ្វើបាបខ្មែរយើង ។

ឈុនលី ៖ ព្រោះយើងនៅលើដីគេ?

ថេង ៖ យើងនៅលើដីគេ ដឹងស្រាប់ហើយ ប៉ុនកាលនោះគឺយើងមានការរស់នៅជាធម្មតា តែគ្រាន់ថា ។

អ្នកជិតខាង ៖ នៅក្នុងរង្វង់ តែចេញទៅគេទាស់តែពីសតែពាស ។

ឈុនលី ៖ ចឹងបានន័យថាជំរំនឹងនៅក្នុងនឹង?

ថេង ៖ បាទ! កាលណាយើងចេញឆ្ងាយ ដាច់ទៅរកអុស ប៉ះណាវាទាស់វាធាក់វាវ៉ៃដែរ ។

ឈុនលី ៖ ធ្លាប់មានដែរ ចុះដែលមានវ៉ៃដល់ស្លាប់?

ថេង ៖ បាញ់សម្លាប់ប្តីបងនេះ ឃឹម មិនសម្លាប់ ។

ឈុនលី ៖ ចុះគាត់ចូលទៅធ្វើអីបានចឹង?

ថេង ៖ ប្រពន្ធគាត់សម្រាលទៅកាប់បន្ទាយកមកដាក់ យកមកស្រះកន្លែងសម្រាល មិនឆ្ងាយទេ ចេញដីប្រហែល១៥០ម៉ែត្រ ។

ឈុនលី ៖ ជិតនេះហ្នឹង?

ថេង ៖ បាទ! វាបាញ់ថានាឡិកាមាស នាឡិកាអី បាញ់ប្លន់យកនាឡិកា ។ ចឹងវាធ្វើបាបយើងគ្រប់បែបយ៉ាងដែរនឹង ។

ឈុនលី ៖ គេធ្វើរបងទៀត?

អ្នកជិតខាង ៖ គេមិនធ្វើរបង ដូចថាមានព្រំប្រទល់ដូចថាផ្ទះយើងចេះ យើងអត់ធ្វើរបង ប៉ុនគ្រាន់ថាយើងដឹងព្រំប្រទល់ជំរំយើងនឹងណា បើចេញទៅសុទ្ធដីថៃគេធ្វើចំការ ធ្វើស្រែ ។ ប៉ុនគ្រាន់ថាយើងចេញហួសរង្វង់ដែលគេកំណត់ឲ្យនឹង ។

ឈុនលី ៖ ចឹងដូចការហូបចុកគ្រប់គ្រាន់ដែរ?

ថេង ៖ បើដូចថាខ្ញុំមោទនភាពតិច ប៉ុន្តែបើនិយាយឲ្យចំអ្នកតស៊ូកាលនោះគ្មានព្រួយបារម្ភដូចរាល់ថ្ងៃនេះ ចាប់ពីក្បាលរហូតដល់ចុងជើង គឺយើងអត់មានទិញម៉ារៀល បើអង្ករមានតែយើងយកទៅលក់ បើនិយាយពីអង្ករវិញ ។

ឈុនលី ៖ អានឹងពេលនៅជំរំ?

ថេង ៖ បាទ!

ឈុនលី ៖ ម៉េចក៏សំបូរម៉្លេះ?

ថេង ៖ កាលនោះវាផ្តល់មកគ្រប់ ។

ឈុនលី ៖ ខាងណាអ្នកផ្តល់?

ថេង ៖ ការពិតទៅថ្នាក់លើ ទំនាក់ទំនងខាងលើមិនដឹងខាងណាដែរ ប៉ុន្តែខ្ញុំគ្រាន់ដឹងថាប្រទេសមួយដែលគេអាចផ្តល់ឲ្យយើងច្រើនជាងគេ គឺចិន ។ បន្ទាប់មកគឺថៃ បន្ទាប់មកទៀតមានក្រុមកាកបាទក្រហមនេះឯង គឺមានបារាំង។ គេជួយមនុស្សធម៌ទេ ។ ដល់ពេលរួមគ្នាមកទៅគឺវាច្រើនណាស់ ក្រណាត់ខោអាវវាមិនខ្វះទេ ដូចរាល់ថ្ងៃមានប្រាក់ខែមែន ប៉ុនព្រួយបារម្ភណាស់ អ្នកក្រោយបើកប្រាក់ខែមក អត់ម៉ាខែគឺដាច់ខ្យល់ ។

ឈុនលី ៖ ចាយសល់ថ្ងៃ?

ថេង ៖ បាទ! ខ្ញុំមិនលើកអី មិនអួតទេ ប៉ុនថាវាជាក់ស្តែងចឹង សួរទៅសួរបងប្អូនយើងកាលនោះ ។

ឈុនលី ៖ ពូបើសិនជាគិតដល់ពេលបច្ចុប្បន្ននេះ អាកាលយើងមានបើករបប វាស្រួលជាងនៅមុខ?

ថេង ៖ វាស្រួល វាមិនព្រួយបារម្ភពីការហូបចុក យើងមិនព្រួយពីជីវភាព ។

ឈុនលី ៖ តែមួយណាល្អជាងស?

ថេង ៖ យើងគិតថាវាម្យ៉ាងម្នាក់ យើងមានហូបចុកមែន ក៏ប៉ុន្តែយើងព្រួយបារម្ភរឿងស្លាប់សង្រ្គាម ព្រួយបារម្ភការបែកបាក់ប្រពន្ធកូន ធ្វើឲ្យមេម៉ាយកំព្រាកូនចៅ ។ បច្ចុប្បន្ននេះ វាព្រួយបារម្ភការហូបចុក និយាយរួមទៅខាងសេដ្ឋកិច្ច បើយើងមិនរកទេ យើងអត់ទៅពឹងអ្នកណាបានដូចយើងរកខ្លួនឯងទេ ចឹត្បិតរដ្ឋាភិបាលខំជួយខំឲ្យបងប្អូននោះខំរកកន្លែងដីធ្លីបង្កបង្កើនផល ។ ប៉ុនអ្នកខ្លះធ្វើទៅខ្ចីលុយគេជំពាក់គេរាល់ថ្ងៃ អ្នកខ្លះមានដីច្រើនមែន តែខ្ចីលុយគេវាន់-ក ។

អ្នកជិតខាង ៖ យ៉ាងច្រើនបើសិនយើងមិនលក់ មិនកាត់លក់ខ្លះម៉េចដោះគេរួច ។

ថេង ៖ បាទ! វាចឹង អានេះវាម្យ៉ាងម្នាក់ ប៉ុន្តែគ្រាន់ថាវានេះជាប្រពៃណីរបស់យើង សុខចិត្តឲ្យវាចឹង ប៉ុន្តែបងប្រធានភូមិខាងឃុំក្រុមប្រឹក្សាស្រុកអី មិនព្រងើយកន្តើយទេ ចឹងបានយើងបង្កើតខាងតំណាងក្រុមមួយសម្ភាសន៍រកប្រជាជនដែលក្រ ចង់ដឹងថាក្នុងមួយឆ្នាំទៅមួយឆ្នាំប្រជាជនក្រប៉ុន្មានភាគរយនៃអ្នកមាន ហើយអ្នកក្រនឹងយើងជួយតាមរយៈអីខ្លះ ហើយដើម្បីចូលរួមកាត់បន្ថយក្រីក្រជាមួយរដ្ឋាភិបាលចឹង យើងនៅយកចិត្តទុកដាក់ចឹង ។ ប៉ុនថាតំបន់នេះខ្ញុំថាបើសិនអ្នកខ្ជិលម៉ង ព្រោះអ្នកក្រខ្លះខ្ញុំឃើញថាក្រ ប៉ុន្តែមិនសូវចេះសន្សំ ប៉ុនអ្នកខ្លះខំ ខ្ញុំឃើញអ្នកខ្លះខំប៉ុនធ្វើវាមិនត្រូវ ឧទាហរណ៍ថាមកពីអីមកពីរឿងធម្មជាតិចឹង ។ ខំឆ្នាំនេះ ឆ្នាំនេះថា សណ្តែកឆ្នាំនេះអញត្រូវគោន ត្រូវមែនទែនហើយ ដល់ពេលភ្លៀងវាវមកមានអី

សណ្ដែកសៀងគ្នាកំពុងទុំខូចអស់ ។ ចឹងជំពាក់ទីលុយគេនឹង រកសងទៀត ។ ប៉ុនអានេះអត់មានបន្ទោសថាការទេ ព្រោះយើងទាមទារយកសង្គមនឹង លទ្ធិប្រជាធិបតេយ្យ ។

ឈុនលី ៖ តែពូចូលចិត្តសង្គមនឹងជាង?

ថេង ៖ បាទ! ព្រោះអីសង្គមនេះវាទូលាយ ហើយវាផ្ដល់សិទ្ធិឲ្យយើង ផ្ដល់សិទ្ធិគ្រប់បែបយ៉ាងទាំងអស់ ទាំងពីសិទ្ធិទាមទារ តស៊ូមតិ តស៊ូរាល់បញ្ហាទាំងអស់ គឺវាអត់មានអ្នកណាមួយចាត់ថ្នាក់ចោទប្រកាន់ថាយើងនេះជាស្អី១ ដូចខ្ញុំមានមតិចឹង ខ្ញុំមានមតិដោយត្រង់ ។

ឈុនលី ៖ យើងមតិផ្ទាល់ខ្លួន?

ថេង ៖ បាទ! ផ្ទាល់ខ្លួន ហើយត្រង់ ហើយក៏មិនលំអៀងនៅខាងណាដែរ ពូថាខាងនេះធ្វើម៉េចមិនចឹងថាចឹង បើដូចពីដើមវិញដូចម៉ាក់ខ្ញុំគេចោទហើយថាឯងខ្សែខាងនេះខាងនោះមិនចឹង រញ៉េរញ៉ៃគេគុំយកឯងទៅដាក់គុកបាត់ទៀតហើយ ។

ឈុនលី ៖ តាមដល់ផ្ទះ?

ថេង ៖ បាទ! ហើយខ្ញុំជឿជាក់ថា នៅសង្គមនេះវាមានអង្គការក្រៅរដ្ឋាភិបាល ដើម្បីចង់ដឹងចង់យល់អំពីស្ថានភាពរស់នៅផ្ទាល់ ហើយនឹងស្ថានភាពពីដើម ដើម្បីយកមកចុះជាកាសែតចុះជាស្អីមកដោះស្រាយរកការពិត ។

ឈុនលី ៖ ធ្វើសៀវភៅធ្វើស្អី?

ថេង ៖ បាទ! ពីប្រជាពលរដ្ឋ ហើយនឹងជូនដល់អង្គការសហប្រជាជាតិម៉ាផ្នែកទៀត ។ ខ្ញុំថាបើសិនជាមិនមានអង្គការក្រៅរដ្ឋាភិបាលចុះជួយជ្រុំជ្រែង ប៉ុននឹងទេសង្គមជាតិយើងក៏ពិបាក ជួនកាលទៅ...មិនមកមើលផ្ទាល់ភ្នែកផង ....ថាគ្រប់ថាគ្រាន់ចេះមកការពិតទៅគេចុះមកមើលជាក់ស្ដែងនឹងឃើញការលំបាក ។ ហើយចឹងប្រជាជនគាត់មួយចំនួនគាត់នៅតែលំបាករហូតនឹង ។

ឈុនលី ៖ តែប្រជាជននៅនេះភាគច្រើនប្រកបរបរចំការចឹងទៅ ភាគច្រើន?

ថេង ៖ បាទ!

ឈុនលី ៖ ភាគច្រើន?

ថេង ៖ បាទ! ខ្ញុំសុំនិយាយថា...បើខ្ញុំឧទាហរណ៍ពីអ្នកមានបងប្អូននៅស្រុកអាមេរិច ខ្លះអត់មកហ៊ានចង់ទេ ទឹកដីម៉ាឡៃ ។

ឈុនលី ៖ ខ្លាចអី ខ្លាចសង្គ្រាម?

ថេង ៖ គេថាខ្លាចណាស់ គេមិនខ្លាចសង្គ្រាមទេ គេថាព្រោះវាធ្លាប់ជះឥទ្ធិពលអាក្រក់ គេថាខ្មែរក្រហមឃោរឃៅមិនចឹង ។ ចឹងទោះបីឯងមានបងប្អូន៤-១០នៅនឹង អញមិនមកដែរគេថា

ចិន ៗ ប៉ុនដល់ពេលបានមកម្តង គេថាល្អជាងស្រុកណាទៀត ព្រោះស្រុកនេះវាមិនចេះកាប់សម្លាប់គ្នា មិនចេះនេះគ្នាទេ ចេះតែជួយគ្នា ៗ ហើយមានបងប្អូនមកពីក្រៅចិនមក ស្រាក់សស្រាំមកហើយ មិនចិន ៗ សួរគ្នាយីចុះឯងមកសួរសុខទុក្ខគ្នាទៅវិញទៅមកទៅប្រើទៅ ហើយប្រាប់ទៅថាគ្នាមិនដែលមានបញ្ហាអីទេ គេក៏អរទៅ ៗ ថាដល់គេមក២-៣នាក់ចិនទៅវិញក៏គេដឹងគេមកទៅ ៗ

ឈុនលី ៖ គាត់មកតៗគ្នា?

ថេង ៖ បាទ!

ឈុនលី ៖ ពូមានអារម្មណ៍ម៉េចដែលនៅពេលដែលគេនិយាយថាធ្លាប់ជាតំបន់អាក្រក់អីចិន គេគិតថាខ្មែរក្រហម?

ថេង ៖ មាន បាទ! មាន ខ្ញុំគិតថាចេះ បើសិនជានៅ បើសិនម្នាក់ៗនៅតែទប់នៅក្នុងអារម្មណ៍ចិនថាខ្មែរក្រហមវាអ្នកឃោរឃៅដូចគេនិយាយចិន ៗ ចិនឲ្យតែខ្មែរក្រហមទៅកន្លែងណា ក៏គេមិនចិនដែរ ដូចថាខ្ញុំចិនៗខ្ញុំមានអ្នករាប់អាននៅខាងខេត្ត ដល់គេដឹងថាខ្ញុំខ្មែរក្រហម អ្នកខ្លះថាខ្មែរក្រហមមិនល្អ ចុះរាប់អានអីជាមួយវា ៗ ប៉ុនដោយសារបងប្អូននៅខេត្តនោះមិនអីព្រោះចូលចិត្តៗព្រោះយើងថានិយាយពិត ធ្វើអីពិតដែរ ៗ និយាយចិនវាមិនមែនឲ្យប៉ះពាល់ដែរ ព្រោះរដ្ឋាភិបាលចង់ធ្វើចិន ៗ ឧទាហរណ៍ថាការបង្កើតជាអង្គភាពកងទ័ពមួយ គេឲ្យបង្កើត១៥០នាក់ យើងរំរកមនុស្ស១៥០នាក់ ៗ ដល់គេបើកបៀវត្សរ៍មក តែ១១០នាក់ទេ វាបាត់៤០ សួរថាយើងដោះស្រាយអីឲ្យគេ ដល់យើងទៅតវ៉ាដល់ខេត្ត គេថាខ្ញុំឲ្យបង្កើត១៥០ ប៉ុនលោកឯងបង្កើត១៥០ ម៉េចមិនបង្កើត១១០ អ្នកឯងម៉េចក៏មិនប្រាប់យើង ៗ ចាំបាច់ប្រាប់ យកតែពួកអាម៉ូតូឌុប៤០នាក់មក ថតរូបវាទៅឲ្យម្នាក់១០០ទៅ ចាំប្រាក់ខែគេកាត់ឲ្យយើងវិញ ៗ ខ្ញុំថាខ្ញុំមិនធ្វើចិនបានទេ តែ១៥០ៗហើយ ហើយក៏មិនដែលមានម៉ូតូពីណាមកដែរ គឺសុទ្ធតែពួកទ័ពនឹង ឥឡូវអ្នកឯងធ្វើម៉េច ៗ

ឈុនលី ៖ ធ្វើទ័ពមែន?

ថេង ៖ បាទ! អ្នកឯងធ្វើម៉េចរកប្រាក់ខែ រកបៀវត្សរ៍ឲ្យ៤០នាក់នឹងទៅ ទម្រាំដោះស្រាយបានគេថាឥឡូវនេះបញ្ចូលទៅខាងកងពល ព្រោះកងពលខ្វះមនុស្សកុំអីងាប់ខ្ញុំ ៗ ខ្ញុំថានៅម៉ាឡៃអត់មានដូចនឹង អត់មានស៊ីប្រាក់ខែណាម៉ាបាតទេ ប្រាក់ខែបងប្អូនទទួលបានប៉ុន្មាន ខ្ញុំឲ្យប៉ុននឹង ៗ បើខ្ញុំសូមបងប្អូនឲ្យប៉ុន្មានឲ្យមកសុំ២០បាត ខ្លះគេឲ្យដល់៥០បាត សុំគេវិញ ៗ ចិនបានខ្ញុំថានៅស្រុកម៉ាឡៃនេះ គេស្រឡាញ់ត្រង់ថាមនុស្សត្រង់ ៗ

ឈុនលី ៖ ចិននៅនេះអត់ដែរមានចោរ?

ថេង ៖ អត់ទេ វាទើបឥឡូវទេ ឥឡូវស្ងប់វិញ ។

ឈុនលី ៖ ដូនកាលសំបូរម៉ាសារ ៗ ?

ថេង ៖ វាចេះ តាំងពីយើងធ្វើសមាហរណកម្មមក មនុស្សច្រើនៗ បើថាពួកនៅនេះសុទ្ធតែគ្មាន ដូច លោកណុត សារអាងរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ។ ដែលស្គាល់គាត់?

ឈុនលី ៖ ធ្លាប់ឮឈ្មោះ ។

ថេង ៖ គាត់លើកៗច្បាស់ចឹងម៉ង គាត់លើកខ្ញុំទៅភ្នំពេញជួបគាត់នឹង គាត់ថានៅស្រុកម៉ាឡៃឯងទុក ម៉ូតូចោលនៅវាលចំការក៏គ្មានអ្នកណាប៉ះពាល់ដែរ ពួកនឹងវាលើកថា កាលនោះវៀនពួកវា មកលួចដីយើង លួចដីពួកខ្ញុំ ។ ស្រុកម៉ាឡៃ បើគ្មានពួកឯងមកដែលបាត់អីទេ ពីដើមទុកម៉ូតូ ទុកវាលស្រែក៏គ្មានបាត់ដែរ ការពិតពួកឯងចូលមកទេ ទើបបាត់ស្រុកម៉ាឡៃ ។ ចឹងដីនឹងឯង ឈប់លូកលាន់គេទៅ ឲ្យគេវិញទៅ ។ គេទៅប្ដឹងពួកយើងថាយើងប្លន់ដីគេ ។ ដល់ពេលសួរ ទៅថាស្រុកឯងនៅណា ខ្ញុំនៅព្រះនេត្រព្រះ ខ្លះនៅស្វាយស៊ី សេរីសោភ័ណ្ឌអីនឹង ហើយចុះ ម៉េចបានមានដីនៅម៉ាឡៃដែរ ថាខ្ញុំទៅសុំគាត់ ។ ចុះម៉េចទៅប្ដឹងថាគាត់នឹងទៅប្លន់អ្នកឯងវា ចឹង ។ ហ្នឹងថារដ្ឋាភិបាល គាត់អត់ដឹងទាំងអស់ទេ ព្រោះអ្នកខ្លះយកអំណាចរបស់គាត់យក មកប្រើប្រាស់សង្កត់សង្កិនលើប្រជាជនអ្នកស្លូតត្រង់... បំផ្លាញពួករដ្ឋាភិបាល ។

ឈុនលី ៖ ពូខ្ញុំចង់ដឹងដូចថាបើប្រជាជនគេគិតថាខ្មែរក្រហមអាក្រក់ចឹង ហើយពូគិតថាដើម្បីឲ្យពួកគាត់ គិតថាយើងមនុស្សល្អ ផ្សះផ្សាគ្នាវិញ យើងចង់ផ្សះផ្សាគ្នាវិញ យើងគួរតែផ្សះផ្សាដោយ យើងរស់នៅជិតគ្នា ឬមួយក៏រស់នៅឆ្ងាយពីគ្នា មួយណាងាយស្រួលនឹងត្រូវរ៉ូវគ្នាជាង?

ថេង ៖ ខ្ញុំថាបងប្អូនយើងនៅនេះ សុទ្ធតែម្នាក់ៗស្រុកភូមិផ្សេងគ្នា ចឹងចាប់ពីពេលនោះមកដល់ពេល នេះ គេដឹងហើយ គេដឹងបណ្ដើរៗ ខ្ញុំអ្នកនៅនឹងប៉ុនខេត្តខ្ញុំនៅក្រចេះ ។ ដល់ពេលខ្ញុំដល់ ក្រចេះផ្សព្វផ្សាយអ្នកក្រចេះគេមិនដឹង ។ ហើយបងគាត់នៅខាងខេត្តកណ្ដាល នៅខាង តាកែវ ខាងកំពតចឹងឥឡូវនឹងផ្សព្វផ្សាយរហ័ស ហើយបងប្អូនគេមកពពាក់ពពូនទាំងអស់គ្នា វាអាច គេដឹងថាស្រុកម៉ាឡៃមិនដូចអ្នកខ្លះគេថាទេ វាសឹកដល់៩០ភាគរយទៅហើយឥឡូវ នេះ ។

ឈុនលី ៖ ចឹងទោះបីជិតឆ្ងាយអី វាមិនសំខាន់?

ថេង ៖ វាគ្រាន់ថានៅម៉ាបែកគិចតូចទេ ដែលថាគាត់នោះគ្មានបងប្អូនទាល់តែសោះ ហើយគាត់ជា មនុស្សដែលធ្លាប់មានដែលវិបត្តិសង្គម ដូចថាកាលសម័យ៣ឆ្នាំសម្លាប់មនុស្ស ហើយគាត់ នោះឯង គាត់ធ្លាប់នៅភ្នំពេញ ក្រោយមកគេដកគាត់ចេញពីភ្នំពេញទៅនៅតាមជនបទ ។ ចឹងដល់ពេលទៅនៅជនបទគាត់មិនស្គាល់អស់បងប្អូនកូនចៅគាត់ ចឹងគាត់នៅសល់ម្នាក់២នាក់

គាត់ត្រឡប់មកនៅភ្នំពេញវិញ ។ ដល់គេដែនការកាត់ខ្មែរក្រហមនឹង គាត់នោះឯងខឹងខ្មែរក្រហមនោះ អាចតែប៉ុន្មាននាក់នឹងទេ សួប់ខ្មែរក្រហមប៉ុនបើគាត់យល់ថាខ្មែរក្រហមអ្នកណាបង្កើតទៅវិញ គឺគាត់អត់ខឹងទេ អ្នកណាអ្នកដាក់ឈ្មោះ ដាក់ពណ៌ឲ្យបើគាត់ដឹងគឺអត់ៗ បើស្អប់ជាបុគ្គលស្អប់ទៅចុះ ។ ថាឥឡូវយើងសុខចិត្តថាឲ្យកាត់ទោសហើយ ឥឡូវកាត់ទោសដល់អ៊ំអៀង សារីទៀត ០០២នេះថ្មីៗនេះកាត់ទោសទៀតហើយ ។

ឈុនលី ៖ ខួងឆ្នាំក្រោយ?

ថេង ៖ បាទ!

អ្នកជិតខាង ៖ និយាយរួមអ្នកម៉ាខ្សែនៅនេះ ដូចខ្ញុំអត់មានបងប្អូននៅនេះទេ ខ្ញុំនៅទួល... ។

ឈុនលី ៖ ខាងខេត្តកណ្ដាល?

អ្នកជិតខាង ៖ បាទ!

ឈុនលី ៖ ខាងស្រុកអីគេវិញ?

អ្នកជិតខាង ៖ ខ្ញុំនៅភូមិព្រែកអំពិល ជិតព្រែកលួងនោះ ។

ឈុនលី ៖ ស្រុកអីគេ?

អ្នកជិតខាង ៖ ស្រុកខ្សាច់កណ្ដាល ។

ឈុនលី ៖ ខ្សាច់កណ្ដាល?

អ្នកជិតខាង ៖ ហ្នឹងហើយ ប៉ុនបើនៅចេះទៅវានៅចំរុះគ្នាមកពីខេត្តនេះខេត្តនោះទៅ វាទៅជាសាច់ញាតិ ចង់ជាងបងប្អូនឯងបង្កើតទៀត អាយើងអ្នករាប់អានគ្នាចង់ជាងបងប្អូនបង្កើតទៀតមិនធម្មតាទេ ។

ឈុនលី ៖ ព្រោះយើងធ្លាប់នៅជាមួយគ្នាយូរហើយ?

អ្នកជិតខាង ៖ ហ្នឹងហើយ អាចឹងបានថាអ្នកនៅនេះ ឲ្យទៅនៅក្នុងវិញ អត់នៅបានទេ អត់ចេះរកស៊ីទេ ព្រោះយើងធ្លាប់នៅភ្នំធ្លាប់រកស៊ីបាន ប៉ុនមកនេះអត់សូវចេះ ដល់យើងទៅវិញអត់កើតទេ សុខចិត្តមកនេះវិញហើយ ។

ឈុនលី ៖ ពូចឹងដែរ បើឲ្យទៅនោះម៉េចទៅ?

ថេង ៖ ហ្នឹងមិនរួចដែរទេ បងខ្ញុំថាទៅគាត់ទិញដីទល់មុខទន្លេ ដីចិនដីនឹងកាលនឹងដូចថាថោកនឹង៥០០០ដុល្លា គាត់ទិញដីនឹងធំ ឥឡូវរាប់ម៉ឺនដុល្លា ។ គាត់ទិញកាលនឹងតែ៥០០០ដុល្លាឲ្យខ្ញុំទៅនៅហើយធ្វើផ្ទះឲ្យទៀតឯងមិនបាច់ចាំធ្វើអីទេ ឲ្យទៅនៅមើលឈើ ព្រោះនៅកន្លែងនោះលក់កូនឈើ ។ ដីថៃយើងទៅធ្វើស្រែធ្វើអីនៅនោះ ហើយអូរនេះយើងមានដែនការបិទទំនប់ហើយជីកប្រឡាយឲ្យវាមានប្រឡាយហែលៗឲ្យវាមានទឹកហូរកាត់ទៅជាអូរទៅជាព្រំដែនថ្មី ចឹងអា

អូរនេះគេលុបចោលណា ។ ចឹងប៉ុនកាលនោះយើងមកនៅ យើងរុញចេញយើងស្គាល់ច្បាស់ណាស់ ថាមិនមែនព្រំដែននៅអូរទេ គឺព្រំដែនហួសអូរទៅនៅនោះទៀត យើងដឹងហើយណា ឆ្នាំ១៩៦២ កាលនឹងដល់យើងឈ្នះក្តីនៅទីក្រុងឡាអេ គឺនៅនោះទេ វានៅកាត់ស្រុកអារញ្ញនោះ ក៏ប៉ុនថាយើងឲ្យមកនៅព្រំដែននេះវាប្រសើរហើយហើយវាចង់យកដល់នោះទៀត ។ យើងមើលកន្លែងខ្លះខុសពីតំបន់ខ្មែរក្រហម ឲ្យតែមិនតំបន់ខ្មែរក្រហម គឺថៃយកច្រើនណាស់ ថៃយកច្រើន ។

ឈុនលី ៖ និយាយទៅថៃវាឈ្លានពានមែនទែន ដល់សម័យឥឡូវនៅចង់បានប្រាសាទចង់បានអីទៀត?

ថេង ៖ ស្តេចថៃនឹងមានមហិចតាយូរហើយ ព្រោះថាមុននឹងវាប់ទៅធ្វើម៉េចទាមទារយកវិញ យកប្រាសាទមិនមែនត្រឹមប្រាសាទព្រះវិហារទេ ដូនកែវជាទឹកដីរបស់វា ព្រោះអីកូនចៅទៅសួរទៅ នឹងអ្នករៀននឹងសួរថាដូនកែវដីអ្នកណា ដីថៃ ។

ឈុនលី ៖ ដូនកែវ?

ថេង ៖ ស្វាយដូនកែវ ។

ឈុនលី ៖ ស្វាយដូនកែវ ខេត្តពោធិ៍សាត់?

ថេង ៖ បាទ! ហ្នឹងវាបោះព្រំនៅនឹង ក្នុងសម័យលន្នែក ១៩៤៩ដែលយកលន្នែកយើងបាន ។ ចឹងផែនការរបស់វា អាស្តេចថៃនេះមិនធម្មតាទេ អាផាស៊ីននេះវាគោរពតាមគោលការណ៍ស្តេចណាស់ ។

ឈុនលី ៖ ចឹងបានចេះតែមានជម្លោះនៅថៃ ។

ថេង ៖ ចុះបើមើលពេលវាកែៗអាផែនទីនេះ វាគូរដោយឯកតោភាគី វាយកឲ្យយើងអនុវត្តតាមអាផែនទីនឹង យើងមិនទៅយកណា យើងយកតាំងពី១៩០៤ ១៩០៩ ១៩០៧ ។ មុនដែលយើងឈ្នះក្តីនៅទីក្រុងឡាអេ យកអានឹងមក ដែលកាលនោះវាគេហៅផែនទីបារាំងសៀម ។ ហើយវាមិនយកអានឹងមកលើកណា វាយកអាផែនទីមកគូសថ្មី ហើយដាក់ផែនការឲ្យទាហាននៅ ហើយវាថាយើងទៅនៅលើទឹកដីវា ។ ហើយកុំថាវាចង់បានតែប្រាសាទព្រះវិហារមិនមែនទេ ។

ឈុនលី ៖ ចឹងដូចជាអស់ហើយគ្មានសួរពូទៀត អរគុណ ។

«ចប់»